# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
# របាយការណ៍វឌ្ឍនភាពប្រចាំខែ មករា និងខែ កុម្ភៈ ឆ្នាំ ២០០៩

របាយការណ៍វឌ្ឍនភាពប្រចាំខែនេះ មានគោលដៅដើម្បីត្រួតពិនិត្យ និងតាមដានការអនុវត្តសកម្មភាព ដែលបានកំណត់នៅក្នុងផែនការសកម្មភាពរបស់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងផែនការសកម្មភាពរបស់ក្រសួង-ស្ថាប័ន នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី ២។

## ១. វឌ្ឍនភាពលើចង្កោមសកម្មភាពនៃផែនការសកម្មភាពដំណាក់កាលទី ២

| លទ្ធផលសម្រេចបានក្នុងខែ | ភាគរយនៃលទ្ធផលសម្រេចបានធៀបនឹងគោលដៅ |
|---|---|
| **ក្រុមចំណូល** | |
| ១១.១: កែសម្រួល និង អនុវត្ត គោលនយោបាយចំណូល រយៈពេលមធ្យម រួមទាំង ឧស្ម័ននិងប្រេងកាត | |
| • បន្តពិនិត្យឡើងវិញសេចក្តីព្រាងច្បាប់កាស៊ីណូដែលមានស្រាប់សំរាប់ពន្លឿននូវការអនុម័ត។<br>• សិក្សាលើការបង់សួយសារ ឬ វិភាគទានផ្សេងៗរបស់ក្រុមហ៊ុនធ្វើអាជីវកម្មប្រេង និង ឧស្ម័ន តាមទម្លាប់អនុវត្តជាអន្តរជាតិ<br>• ប្រកាសស្តីពីការធានារ៉ាប់រងអាយុជីវិតត្រូវបានអនុម័ត ថ្ងៃ១២/០៨/ ០៨ និងបានផ្សព្វផ្សាយដល់ក្រុមហ៊ុនធានារ៉ាប់រងទាំងអស់<br>• ប្រកាសស្តីពីគោលការណ៍ណែនាំផ្នែកគណនេយ្យត្រូវបានអនុម័តនៅ ថ្ងៃទី ៣០/០៧/០៨ និងបានផ្សព្វផ្សាយដល់ក្រុមហ៊ុន ធានារ៉ាប់រងទាំងអស់<br>• រៀបចំធ្វើសិក្ខាសាលា ដើម្បីផ្សព្វផ្សាយជាសាធារណៈ<br>• ពង្រាងច្បាប់ ស្តីពីការធានារ៉ាប់រងត្រូវបានធ្វើវិសោធនកម្ម<br>• សិក្សាស្រាវជ្រាវចនាសម្ព័ន្ធច្បាប់ស្តីពីការធានារ៉ាប់រងពីប្រទេសអាស៊ាន<br>• ធ្វើទស្សនៈកិច្ចសិក្សាក្រៅប្រទេសដើម្បីស្វែងយល់ពីការរៀបចំច្បាប់ស្តីពីការធានារ៉ាប់រង និង ការអនុវត្ត<br>• សេចក្តីព្រាងអនុក្រឹត្យ ស្តីពីការធានារ៉ាប់រងខ្នាតតូចត្រូវបានបញ្ចប់ និងរង់ចាំការឯកភាពពីឯកឧត្តមឧបនាយករដ្ឋមន្ត្រី<br>• រៀបចំប្រកាសដែលពាក់ព័ន្ធ ដើម្បីគាំទ្រដល់ការអនុវត្តអនុក្រឹត្យស្តីពីការធានារ៉ាប់រងខ្នាតតូច<br>• សេចក្តីព្រាងអនុក្រឹត្យស្តីពីមីក្រូហិរញ្ញវត្ថុត្រូវបានព្រាងរួចហើយ កំពុងពិភាក្សាដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីសំរេច<br>• គោលការណ៍យុទ្ធសាស្ត្រមីក្រូហិរញ្ញវត្ថុ កំពុងដំណើរការបោះពុម្ពសៀវភៅ និងសិក្សាស្រាវជ្រាវបន្ថែម | |
| ១១.៣: បន្តកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធគយ (រួមទាំងវិធានការកែលម្អការ ផ្តល់ព័ត៌មាន និង តម្លាភាពដល់ អ្នកជាប់ពន្ធ និង កម្រៃសេវា) | |

| | |
|---|---|
| • បន្តពង្រឹងការអនុវត្តនលិខិតបទដ្ឋាននានាដែលចូលជាធរមាន ដូចជាក្រមកិរិយាមាទគយ ការរៀបចំបទប្បញ្ញត្តអប្បបរមាដើម្បី ជាជំនួយស្មារតីដល់កិច្ចអនុវត្ត និង លិខិតបទដ្ឋានដទៃទៀតដើម្បីគ្រប់គ្រងដល់កម្មវិធីកំណែទម្រង់<br>• បន្តអនុវត្តនូវគម្រោងអាស៊ីគូដាវើល ជំហានទី៣ ដោយពង្រីកនៅតាមមាត់ច្រកសំខាន់ៗ ដូចជា:<br>-ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភំពេញ<br>-ការិយាល័យគយ និងរដ្ឋាករផែស្ងួត<br>-ការិយាល័យគយ និងរដ្ឋាករនាំចេញ និង ការិយាល័យរដ្ឋាករ<br>• រៀបចំកិច្ចប្រជុំប្រចាំខែដើម្បីធ្វើការណែនាំ និងផ្សព្វផ្សាយនូវកិច្ចការងារសំខាន់ៗ ដល់មន្ត្រីគយនៅគ្រប់មាត់ច្រកដើម្បីអនុវត្ត<br>• ពង្រឹងការអនុវត្តលិខិតបទដ្ឋាន ស្តីពីការប្រមូលសាច់ប្រាក់ត្រូវបង់ផ្ទាល់ចូលក្នុងគណនីរតនាគារនៅក្នុងធានាគារជាតិ<br>• បានបញ្ជូនមន្ត្រីទៅចូលរួមប្រជុំ និង ចូលរួមវគ្គបណ្តុះបណ្តាលនៅក្រៅប្រទេស | |
| ១១.៤: បន្តកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធដារ | |
| • បន្តពង្រឹងការអនុវត្តសារាចរ និង បទប្បញ្ញត្តទាំងឡាយដែលមានជាធរមានសំរាប់គ្រប់គ្រងកាស៊ីណូ និង ពង្រឹងការប្រមូលចំណូល ចូលជាថវិការដ្ឋ<br>• អនុវត្តជាប្រចាំនូវការត្រួតពិនិត្យការលាងលុយនៅក្នុងអាជីវកម្មកាស៊ីណូ ប៉ុន្តែជាការងារមួយថ្មីសម្រាប់មន្ត្រី<br>• គណៈកម្មាធិការចំរុះរវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ដើម្បីបង្ក្រាបល្បែងខុសច្បាប់ត្រូវបានបង្កើត<br>• ***សកម្មភាពមួយចំនួនដែលទាក់ទងនឹងការពង្រឹងនិងគ្រប់គ្រងលើក្រុមហ៊ុនភ្នាល់បាល និង ស្លុតម៉ាស៊ីនត្រូវបានលុបចោលទាំងស្រុង យោងតាមសារាចររបស់រាជរដ្ឋាភិបាលលេខ ០១ សណន ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០៩។***<br>• ធ្វើការងារយ៉ាងជិតស្និតជាមួយវិទ្យាស្ថាន AITRI សំរាប់ជំនួយការបច្ចេកទេសដើម្បីធ្វើឱ្យប្រសើរ ការសម្របសម្រួលអន្តរជាតិ សម្រាប់ជំនួយបច្ចេកទេសដើម្បីគ្រប់គ្រងអាជីវកម្មធានារ៉ាប់រង<br>• ការងាររៀបចំក្របខ័ណ្ឌ គោលនយោបាយនិងយុទ្ធសាស្ត្រសម្រាប់មីក្រូហិរញ្ញវត្ថុត្រូវបានបញ្ចប់<br>• បានសើរើ និងធ្វើវិសោធនកម្មកិច្ចព្រមព្រៀងទាក់ទិននឹងការគ្រប់គ្រងស្ថាប័នមីក្រូហិរញ្ញវត្ថុ<br>• បានរៀបចំសេចក្តីព្រាងតារាងកំរៃជើងសារសំរាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុ ប៉ុន្តែបច្ចុប្បន្នរង់ចាំ ធ្វើការពិភាក្សាជាមួយ សមាគមអ្នកវាយតំលៃអចលនវត្ថុជាតិកម្ពុជា<br>• បានរៀបចំពេលវេលាសំរាប់ចុះត្រួតពិនិត្យតាមដានការអនុវត្តរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាប័ណ្ណ និងក្រុមហ៊ុនដែលប្រកប អាជីវកម្មគ្មានអាជ្ញាប័ណ្ណ ។ បច្ចុប្បន្នមានក្រុមហ៊ុនចំនួន | |

| | |
|---|---|
| ៧៤ បានទទួលអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនោះមាន ក្រុមហ៊ុនចំនួន ១៤ បានបន្តអាជ្ញាប័ណ្ណដែលអស់សុពលភាព<br>• បានរៀបចំសេចក្តីព្រាងក្រមសីលធម៌វិជ្ជាជីវៈសំរាប់ក្រុមហ៊ុនប្រកបសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុប៉ុន្តែបច្ចុប្បន្នរង់ចាំធ្វើការពិភាក្សាជាមួយសមាគមអ្នកវាយតំលៃអចលនវត្ថុជាតិកម្ពុជា<br>• បានរៀបចំសេចក្តីព្រាងស្តង់ដារវាយតំលៃអចលនវត្ថុ ប៉ុន្តែបច្ចុប្បន្នរង់ចាំធ្វើការពិភាក្សាជាមួយសមាគមអ្នកវាយតំលៃអចលនវត្ថុ ជាតិកម្ពុជា<br>• សមាគមអ្នកវាយតំលៃអចលនវត្ថុត្រូវបានបង្កើត ហើយបានសម្ពោធជាផ្លូវការកាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ២០០៩<br>• ក្រុមការងារអន្តរក្រសួងដើម្បីគ្រប់គ្រងអាជីវកម្មអភិវឌ្ឍន៍អចលនវត្ថុ ត្រូវបានបង្កើត តាមប្រកាសលេខ ២១៦ សហវ.ប្រកឧហ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ២០០៨<br>• ប្រកាសលេខ ៥៤៨ សហវ.ប្រក ចុះថ្ងៃទី ៣០ ខែ កក្កដា ឆ្នាំ២០០៨ ស្តីពីការគ្រប់គ្រងការត្រួតពិនិត្យ និង ការផ្តល់អាជ្ញាប័ណ្ណជូន បុគ្គលអភិវឌ្ឍន៍អចលនវត្ថុ ត្រូវបានចុះហត្ថលេខា ប៉ុន្តែបច្ចុប្បន្នប្រកាសនេះមិនទាន់អនុវត្តបាននៅឡើយ ដោយរង់ចាំសារាចរណែនាំ អនុវត្តប្រកាសនេះរៀបចំរួចរាល់សិន<br>• បានរៀបចំសេចក្តីព្រាងបទប្បញ្ញត្តិមូលប័ត្រ ( តម្រូវការលើការចុះបញ្ជីវិធាន លើការធ្វើទិញដូរដោយដេញថ្លៃការបើកបង្ហាញ ព័ត៌មានរបស់សាជីវកម្ម និង វិធាននិងលក្ខខណ្ឌដើម្បីផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលប័ត្រ និងការិយាល័យតំណាងរបស់ខ្លួន )<br>• សេចក្តីព្រាងអនុក្រឹត្យស្តីពីការចេញផ្សាយនិងធ្វើពាណិជ្ជកម្មមូលប័ត្រមិនមែនរដ្ឋាភិបាល ត្រូវបានផ្ញើទៅក្រសួងពាណិជ្ជកម្ម ។ | |
| ១១.៥: បន្តកែលម្អគោល នយោបាយចំណូលមិនមែនពន្ធ និង រដ្ឋបាល ដោយរួមទាំង ទ្រព្យសម្បត្តិរដ្ឋ | |
| • ចូលរួមពិនិត្យ និង កែសម្រួលខ្លឹមសារគោលនយោបាយគៀងគរចំណូល ផ្តល់យោបល់ស្តីពីទិន្នន័យសំខាន់ៗ ដែលពាក់ព័ន្ធនឹងចំណូល មិនមែនសារពើពន្ធ<br>• បញ្ចប់ការកែសម្រួលប្រកាសអន្តរក្រសួងលេខ ១១៩១ សហវ.ប្រក. ចមព ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៦ ស្តីពី " អាករ បណ្ណ័ ការងារ សៀវភៅការងារ និងកំរៃសេវាពិនិត្យសុខភាព" និងបានដាក់ប្រជុំក្នុងក៏រិតថ្នាក់ដឹកនាំក្រសួង សហវ និង ក្រសួងការងារ ដើម្បីធ្វើការពិនិត្យសំរេច និង ចុះហត្ថលេខា។<br>• បញ្ចប់សេចក្តីព្រាងប្រកាសអន្តរក្រសួងស្តីពី "កម្រៃនៃការចេញលេខប្រវេទន៍ផលិតផលគ្រឿងសំអាង" និង បានដាក់ប្រជុំក្នុងក៏រិត ថ្នាក់ដឹកនាំក្រសួង សហវ- សុខាភិបាល ដើម្បីធ្វើការពិនិត្យសំរេច និង ចុះហត្ថលេខា ។<br>• ប្រមូល សិក្សា និង ពិនិត្យឡើងវិញ ក្របខ័ណ្ឌច្បាប់នានាដែលពាក់ពន្ធ័ នឹងការគ្រប់គ្រងចំណូលមិនមែនសាពើពន្ធ នៅតាមបណ្តា ក្រសួង ស្ថាប័ននានាដែលនៅជាធរមានដើម្បីធ្វើការកែលម្អ ឬ រៀបចំសេចក្តីព្រាងក្របខ័ណ្ឌច្បាប់ថ្មីបន្ថែមទៀត ដើម្បីពង្រឹង ការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ<br>• ពិនិត្យ និង រៀបចំកែលម្អឡើងវិញនូវពាក្យពេចន៍ និងខ្លឹមសារសារាចរណែនាំស្តីអំពីការដាក់ឱ្យអនុវត្តនូវបង្កាន់ដៃជាតិឱ្យមាន សង្គតិភាព ទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីប្រពន្ធ័ហិរញ្ញវត្ថុសាធារណៈ និង លិខិត បទដ្ឋាន<br>• ផ្ញើលិខិតទៅភាគីឯកជន ដើម្បីឱ្យបង់ចំណូលចូលថវិការដ្ឋលើការទិញ និង ដោះដូរទ្រព្យសម្បត្តិរដ្ឋ | |

| | |
|---|---|
| • ពិនិត្យលើលក្ខណៈវិនិច្ឆ័យនានាក្នុងការសំរេចផ្តល់ការលើកទឹកចិត្តចំពោះមន្ត្រីដែលបំពេញការងារប្រមូលចំណូលនៅ : ថ្ងៃឈប់ សំរាក ទីតាំងប្រមូលចំណូលស្ថិតនៅឆ្ងាយ និងចំណូលពីការផាកពិន័យ<br>• សិក្សា និងលើកយោបល់សុំធ្វើកែសម្រួលនីតិវិធីដកប្រាក់រង្វាន់សំរាប់ផ្តល់ការលើកទឹកចិត្ត<br>• ជំរុញចេញប្រកាសអន្តរក្រសួងដែលក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចុះហត្ថលេខា រួចហើយ នាចុងឆ្នាំ២០០៧កន្លងទៅឱ្យចូលជាធរមាន<br>• បានបញ្ជូនលិខិតទៅក្រសួង ស្ថាប័នពាក់ព័ន្ធ និង ភាគីឯកជនជម្រាបឱ្យចាត់ចែង អនុវត្តគោលការណ៍ធ្វើឯកជនភាវូបនីយកម្ម<br>• កំពុងចុះស្រាវជ្រាវ និងពិនិត្យចំណូល-ចំណាយ អង្គភាពរដ្ឋមួយចំនួន ដែលមានលទ្ធភាពអាចចូលជាគ្រឹះស្ថាន សាធារណៈរដ្ឋបាល ( ដូចជា មន្ទីរពេទ្យកុមារជាតិ និងមន្ទីរពេទ្យព្រះអង្គឌួង)<br>• កំពុងធ្វើកំណត់បង្ហាញយកកំរៃពីសេវាសិក្សាបង់ថ្លៃចំនួន ២% ចំពោះសាកលវិទ្យាល័យ២ គឺសាកលវិទ្យាល័យជាតិគ្រប់គ្រង និង សាកលវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច<br>• បានរៀបចំ និង ពិនិត្យផែនការគណនេយ្យប្រចាំឆ្នាំ ២០០៩ របស់សហគ្រាសសាធារណៈទាំងអស់<br>• កំពុងរៀបចំកំណត់យកភាគលាភ នៃប្រាក់ចំណេញរបស់សហគ្រាសមួយចំនួនដែលត្រូវបង់<br>• បានបន្តជំរុញឱ្យក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលគោរពតាមមាត្រា១៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចំពោះការ គ្រប់គ្រងនិងការធ្វើអាជីវកម្មរ៉ែដែលកិច្ចសន្យាសម្បទានរ៉ែត្រូវមានការពិនិត្យ និងឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>• បានបន្តជំរុញឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទគោរពតាមមាត្រា ១៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈចំពោះរាល់កិច្ចសន្យាស្តីពីការជួលដីសម្បទានសេដ្ឋកិច្ចត្រូវមានការពិនិត្យ និង ឯកភាពពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។<br>• កំពុងចាត់វិធានការចំពោះបំណុលស្តីពីការជួលដីសម្បទានរ៉ែ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។<br>• កំពុងជំរុញឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចាត់វិធានការដើម្បីប្រមូលចំណូលពីដីសម្បទានសេដ្ឋកិច្ចដែលពីមុនមកដល់ បច្ចុប្បន្នមិនដែលមានចំណូលសោះ<br>• បានបញ្ចប់ការរៀបចំចាត់បញ្ជូនមន្ត្រីនៃនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ចំនួន៩ក្រុម ទៅកាន់បណ្តាក្រសួង ស្ថាប័នថ្នាក់កណ្តាលដើម្បីសហការការងារគ្រប់គ្រងការអនុវត្តចំណូលមិនមែនសារពើពន្ធប្រចាំឆ្នាំ២០០៩<br>• គណៈកម្មាធិការអន្តរក្រសួង ដើម្បីរៀបចំយន្តការគ្រប់គ្រងចំណូលសេវាចុះបញ្ជីយានយន្ត និង មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ត្រូវបានបង្កើត | |
| ២៩.៥: រៀបចំយន្តការដើម្បី បញ្ចប់ និងធ្វើបច្ចុប្បន្នភាពជា ប្រចាំនូវការចុះបញ្ជីសារពើភ័ណ្ឌ | |
| • បានជំរុញឱ្យក្រសួង-ស្ថាប័ន រាជធានី-ខេត្ត ធ្វើតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង- ថយចុះ ឆ្នាំ ២០០៨ តាមរយៈការ ចេញលិខិត<br>• រៀបចំលិខិតជូនថ្នាក់ដឹកនាំក្រសួងអំពីការកំណត់តម្លៃដី និង អាគារ ដែលបានប្រជុំជាមួយប្រតិភូ IMF ។<br>• ចូលរួមពិនិត្យផ្ទៀងផ្ទាត់តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង-ថយចុះឆ្នាំ ២០០៨ នៅខេត្តព្រៃវែង និង ខេត្តកំពង់ចាម ។ | |

| | |
|---|---|
| • មាត្រាទី ២៥ ដល់ ៤៣ នៃច្បាប់អស្សាមិយករណ៍ ត្រូវបានពិភាក្សារួច ក្រោមការពិភាក្សារបស់ក្រុមប្រឹក្សាគណៈរដ្ឋមន្ត្រី,OBSES និង ក្រុមប្រឹក្សាអ្នកច្បាប់ ។<br>• រៀបចំកំណត់បង្ហាញជូនថ្នាក់ដឹកនាំក្រសួង បញ្ហាកម្មសិទ្ធិទ្រព្យសម្បត្តិរដ្ឋ ដែលពាក់ព័ន្ធជាមួយក្រសួងរៀបចំដែនដី ។<br>• រៀបចំកំណត់បង្ហាញជូនថ្នាក់ដឹកនាំក្រសួង បញ្ហាជំនួយបច្ចេកទេសក្នុងការធ្វើបញ្ជីសារពើភ័ណ្ឌដែលពាក់ព័ន្ធត្រូវពិភាក្សាជាមួយ ក្រសួងរៀបចំដែនដី | |
| ២៨.១: រៀបចំស្ថាប័នដើម្បី ឆ្លើយតបនឹងដំណាក់កាលទី ២ ដោយរួមមាន ការបញ្ចប់ការ ធ្វើការវិភាគមុខងារនៅគ្រប់ នាយកដ្ឋានទាំងអស់នៃ កសហវ និង នៅតាមក្រសួង -ស្ថាប័ន ចំណាយ ។ រៀបចំ និង អនុវត្តផែនការ យុទ្ធសាស្ត្ររបស់នាយកដ្ឋាន នីមួយៗ ។ រៀបចំយុទ្ធសាស្ត្រដើម្បីរៀបចំ និងផ្សព្វផ្សាយឯកសារណែនាំ ស្តីពីប្រពន្ធ ។ ផ្សព្វផ្សាយពី គោលនយោបាយប្រើប្រាស់ ជំនួយបច្ចេកទេសប្រកបដោយ ប្រសិទ្ធភាព ។ ជ្រើសរើសអ្នកជំនាញការដើម្បី គាំទ្រដល់ផែនការកសាង សមត្ថភាព ។ កែលម្អការអនុវត្តការងារតាម រយៈការ បង្កើនការប្រើប្រាស់ បច្ចេកវិទ្យា ។ | |
| • បានចាត់បញ្ជូនមន្ត្រីគយឱ្យទៅចូលរួមវគ្គសិក្សា សិក្ខាសាលា និង ប្រជុំ ទាំងក្នុងប្រទេស និង ក្រៅប្រទេស | |
| **ក្រុមរៀបចំថវិកា** | |
| ២១.១: ពិនិត្យឡើងវិញ និង ធ្វើបច្ចុប្បន្នភាពច្បាប់ និង បទ ប្បញ្ញត្តិ ដែលកំណត់ពីតួនាទី និង ការទទួលខុសត្រូវក្នុងការ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រដ្ឋាភិបាល និងអាចកំណត់ ពីតួនាទីឡើងវិញក្នុងករណីចាំបាច់ | |
| • បានពិនិត្យអំពីសង្គតិភាពរវាងអនុក្រឹត្យដែលមានស្រាប់ គណនេយ្យភាពថ្មី អង្គភាពថវិកា ជាមួយនឹងច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ សាធារណៈឆ្នាំ ២០០៨ | ៥% |
| ២១.៣: កំណត់ពីឱ្យបានច្បាស់ ពីអង្គភាពថវិកា និងអ្នកគ្រប់ គ្រងថវិកា សំរាប់រដ្ឋបាលថ្នាក់ ជាតិ និង ថ្នាក់ក្រោមជាតិ | |
| • បាន និងកំពុងសិក្សាជាបណ្តើរៗលើរៀបចំ និងការប្រព្រឹត្តទៅរបស់អង្គភាពថវិកា ព្រមទាំងអ្នកគ្រប់គ្រងថវិកាសម្រាប់ទាំងថ្នាក់ ជាតិ និងថ្នាក់ក្រោមជាតិ | ៧% |
| ២៣.១: ពិនិត្យមើលឡើងវិញ និង បន្តកែលំអបួងគណនីថ្មី ចំណាត់ថ្នាក់ថវិកាថ្មី នៅក្នុង ការអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | |

| | |
|---|---|
| • បានសិក្សា និងពិគ្រោះយោបល់ជាមួយជំនាញការ IMF អំពីចំណាត់ថ្នាក់ថវិកាដែលកំពុងអនុវត្ត។ ទន្ទឹមនឹងនោះ ក្រុមការងារបាន ផ្តល់យោបល់ ដើម្បីកែសម្រួលរចនាសម្ព័ន្ធនៃចំណាត់ថ្នាក់ថវិកាឱ្យស្របតាមស្ថានភាពជាក់ស្តែងនៅកម្ពុជា ហើយនាយកដ្ឋានថវិកាបានពិនិត្យ និង ឯកភាពលើរចនាសម្ព័ន្ធថ្មីនៃចំណាត់ថ្នាក់ថវិកាដែលនឹងត្រូវរៀបចំកែលម្អ រួមមាន ចំណាត់ថ្នាក់រដ្ឋបាល ចំណាត់ថ្នាក់ សេដ្ឋកិច្ច ចំណាត់ភូមិសាស្ត្រ ចំណាត់ថ្នាក់មុខងារ ចំណាត់ថ្នាក់កម្មវិធី និង ប្រភពនៃហិរញ្ញប្បទាន<br>• បានពិនិត្យ និង ដកស្រង់នូវបញ្ហាមួយចំនួនដែលបានកើតឡើង ដើម្បីបង្ហាញជំនាញការ និងស្នើសុំយោបល់លើការបង្កើតអនុ-អនុគណនី<br>• បានរៀបចំពង្រាងចំណាត់ថ្នាក់សេដ្ឋកិច្ច ជាអនុ-អនុគណនីផ្នែកចំណូល ហើយនឹងដាក់សេចក្តីព្រាងនេះពិភាក្សាជាមួយនាយកដ្ឋានពាក់ព័ន្ធ ។ កិច្ចការដ៏សំខាន់ពីរដែលត្រូវអនុវត្តជាជំហ៊ានដំបូងក្នុងឆ្នាំ ២០០៩នេះ គឺ ១,ការរៀបចំចំណាត់ថ្នាក់រដ្ឋបាល និង ២,ការរៀបចំបង្កើតអនុ-អនុគណនី<br>• បានសិក្សាស្រាវជ្រាវនិងស្វែងយល់ការងារដែលត្រូវធ្វើដោយពិចារណាលើរូមន្តមួយសំរាប់អនុវត្តគឺជំហានដំបូងក្នុងឆ្នាំ ២០០៩ គឺ (១) ការរៀបចំចំណាត់ថ្នាក់រដ្ឋបាល និង (២) ការរៀបចំបង្កើតអនុ-អនុគណនី | ១០% |
| ២៤,២: កែលំអដំណើរការនៃ កិច្ចប្រតិបត្តិនៅក្នុងកសហវ/ ក្រសួង-ស្ថាប័នចំណាយ ដើម្បី ឱ្យស្របទៅតាមការបង្កើតប្លង់ គណនី និងវិធានគណនេយ្យ និងការប្រមូលផ្តុំគណនី ធនាគារជាប្រចាំ | |
| • បានបញ្ឈប់ការចំណាយលើសលទ្ធភាពថវិកាជាតិ និងកាត់បន្ថយឥណទានជាប់សន្សាំចំណាយដែលជាបំណុលកកស្ទះជាបណ្តើរៗ។<br>• សហការជាមួយនាយកដ្ឋានថវិកា និងនាយកដ្ឋានហិរញ្ញកិច្ច រៀបចំអនុក្រឹត្យស្តីពីនីតិវិធីនៃការផ្តល់ប្រាក់បុរេប្រទានសម្រាប់ចំណាយ ចរន្ត និងចំណាយវិនិយោគសាធារណៈ | ៧០% |
| ២៥,២: អនុវត្តការរៀបចំ របាយការណ៍អនុវត្តថវិកា ប្រចាំត្រីមាស ដោយបញ្ជាក់ អំពីលទ្ធផលទទួលបាន ការ យឺតយ៉ាវ និងស្នើឡើងនូវ ដំណោះស្រាយៈ ពីក្រសួង-ស្ថាប័ន ចំណាយ មក កសហវ និង នៅផ្ទៃក្នុង ក្រសួង -ស្ថាប័ន ចំណាយ ពី អង្គភាព ថវិការហូតដល់ថ្នាក់ដឹកនាំ | |
| • បានរៀបចំគំរូរបាយការណ៍សមិទ្ធកម្មនៃការអនុវត្តថវិកា ប្រចាំត្រីមាស ប្រចាំឆមាស និង ប្រចាំឆ្នាំ<br>• បានផ្សព្វផ្សាយដល់ការិយាល័យជំនាញនៃនាយកដ្ឋានថវិកាឱ្យយល់ដឹងពីការរៀបចំរបាយការណ៍នេះ | ៣០% |
| ២៧,១: សិក្សាពីការអនុវត្ត បច្ចុប្បន្ន និង បង្កើតជំរើស សំរាប់ពង្រឹងការរៀបចំ និង អនុវត្តថវិកាសាលារាជធានី- ខេត្ត | |
| បានកែលម្អនីតិវិធីរៀបចំ និង អនុវត្តថវិកាសាលារាជធានី-ខេត្ត តាមរយៈការរៀបចំសារាចរណែនាំស្តីពីនីតិវិធីបច្ចេកទេសនៃការរៀបចំ គម្រោងថវិកា និង សារាចរណែនាំស្តីពីការអនុវត្តថវិកាដើម្បីឱ្យស្របគ្នាទៅនឹងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ | ៧០% |
| ២៧,២: កែលំអចំណូលមិន មែនសារពើពន្ធរបស់រាជធានី- ខេត្ត | |
| • បានរៀបចំសេចក្តីព្រាងលិខិតបែងចែកចំណូលមិនមែនសារពើពន្ធសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានសង្គតិភាពទៅនឹង ច្បាប់ស្តី ពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង | ៥% |

| | |
|---|---|
| ខណ្ឌ និង ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់ រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• បានផ្ញើលិខិតនេះទៅឱ្យនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ និង នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ ដើម្បីផ្តល់យោបល់ | |
| ២៧.៣: កែលំអការរៀបចំ និង អនុវត្តថវិការាជធានី-ខេត្ត/ ស្រុក និង ប្រព័ន្ធគ្រប់គ្រង ហិរញ្ញវត្ថុ | |
| • កំពុងសិក្សាជំរើសពីនីតិវិធីថវិកាស្វយ័ត និង ថវិកាឯកភាពនៅតាមរាជធានី-ខេត្ត<br>• បានរៀបចំសេចក្តីព្រាងលិខិតបែងចែកចំណូលសារពើពន្ធសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឱ្យមានសង្គតិភាពទៅនឹងច្បាប់ស្តីពីការ គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ និង ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ ក្រោមជាតិ<br>• បានផ្ញើលិខិតនេះទៅឱ្យអគ្គនាយកដ្ឋានពន្ធដារដើម្បីផ្តល់យោបល់ | ៥% |
| ២៧.៤: កែលំអការរៀបចំ និង អនុវត្តថវិកា ឃុំ/សង្កាត់ និង ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ | |
| • បានរៀបចំសិក្ខាសាលាពីការអនុវត្តថវិកាឃុំ-សង្កាត់នៅខេត្តកំពង់ស្ពឺ និងខេត្តកំពង់ចាម<br>• បានចងក្រងឯកសារ និង អនុសាសន៍ស្តីពីការកែលម្អអនុវត្តថវិកាឃុំ-សង្កាត់ និងកំពុងសិក្សាលើការកែលម្អប្លង់គណនេយ្យថ្មីសម្រាប់ថវិកាឃុំ-សង្កាត់<br>• បានរៀបចំសេចក្តីណែនាំដើម្បីកែលម្អកិច្ចលទ្ធកម្មសម្រាប់គម្រោងរបស់ថវិកាឃុំ សង្កាត់<br>• បានរៀបចំសេចក្តីព្រាងសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ-សង្កាត់ | ៧0% |
| ២៧.៥: រៀបចំច្បាប់ និង បទ ប្បញ្ញត្តិប្រសិនបើចាំបាច់ដើម្បី គាំទ្រដល់ច្បាប់ស្តីពីការគ្រប់ គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក និង ខណ្ឌ | |
| • បានបង្កើតក្រុមការងារដើម្បីធ្វើវិសោធនកម្មច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិខេត្ត-ក្រុង<br>• ក្រុមការងារបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>• សេចក្តីព្រាងច្បាប់ស្តីរបបហិរញ្ញវត្ថុ និង ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានផ្ញើទៅ គជអប | ៧0% |
| ២៧.៦: រៀបចំយុទ្ធសាស្ត្រ និង គោលនយោបាយវិមជ្ឈការ ហិរញ្ញវត្ថុ ដោយរួមបញ្ចូល ក្របខ័ណ្ឌ និងយុទ្ធសាស្ត្រ សំរាប់កែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ និងកម្មវិធីកែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | |
| • កំពុងសិក្សាលើការរៀបចំយុទ្ធសាស្ត្រយៈពេលខ្លី និង វែង សម្រាប់អនុវត្តវិមជ្ឈការសារពើពន្ធ | ១0% |
| ២៨.១: រៀបចំស្ថាប័នដើម្បី ឆ្លើយតបនឹងដំណាក់កាលទី ២ ដោយរួមមាន ការបញ្ចប់ការ ធ្វើការវិភាគមុខងារនៅគ្រប់ នាយកដ្ឋានទាំងអស់នៃ កសហវ និង នៅតាមក្រសួង -ស្ថាប័ន ចំណាយ ។ | |

| | |
|---|---|
| រៀបចំ និង អនុវត្តផែនការ យុទ្ធសាស្ត្ររបស់នាយកដ្ឋាន នីមួយៗ ។ រៀបចំយុទ្ធសាស្ត្រដើម្បីរៀបចំ និងផ្សព្វផ្សាយឯកសារណែនាំ ស្តីពីប្រព័ន្ធ ។ ផ្សព្វផ្សាយពី គោលនយោបាយប្រើប្រាស់ ជំនួយបច្ចេកទេសប្រកបដោយ ប្រសិទ្ធភាព។ ជ្រើសរើសអ្នកជំនាញការដើម្បី គាំទ្រដល់ផែនការកសាង សមត្ថភាព ។ កែលម្អការអនុវត្តការងារតាម រយៈការ បង្កើនការប្រើប្រាស់ បច្ចេកវិទ្យា ។ | |
| • បានកំណត់ពីមុខវិជ្ជាដែលត្រូវបណ្តុះបណ្តាល និង មន្ត្រីដែលត្រូវបណ្តុះបណ្តាល ហើយបានផ្ញើឱ្យវិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ដើម្បីរៀបចំ | |
| ៣១,៣: អនុវត្តផែនការបណ្តុះ បណ្តាល និងអភិវឌ្ឍសមត្ថភាព សំរាប់អនុវត្តថវិកាតាកម្មវិធី | |
| • នាយកដ្ឋានបានរៀបចំកិច្ចពិភាក្សាលើគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាតាមកម្មវិធី ក្នុងន័យកែលម្អ និង បណ្តុះបណ្តាលដល់មន្ត្រីក្នុង នាយកដ្ឋានអោយមានសមត្ថភាពបណ្តុះបណ្តាល ជាបន្តដល់ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ៥% |
| ៣២,១: រៀបចំគោលនយោ បាយសំរាប់ធ្វើ សមាហរណកម្ម ថវិកា។ បន្តកែលំអការធ្វើ សមាហរណកម្មថវិកាចរន្ត និង មូលធន តាមរយៈការបន្ត អនុវត្តក្របខណ្ឌចំណាយ រយៈពេលមធ្យម (MTEF) ផែនការយុទ្ធសាស្ត្រថវិកា (BSP) និង ថវិកាតាមកម្មវិធី | |
| • គោលការណ៍ណែនាំអំពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP) ត្រូវបានរៀបចំជាសេចក្តីព្រាងចុងក្រោយបង្អស់<br>• នីតិវិធីថ្មីនៃការដាក់ពិន្ទុ និង ការវាយតំលៃលើការរៀបចំផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំឡើង<br>• ចូលរួមជាមួយក្រសួងផែនការ និង ក្រសួង-ស្ថាប័នពាក់ព័ន្ធក្នុងការរៀបចំ PIP ឆ្នាំ ២០១០-២០១២ និងការប៉ាន់ស្មានចំណាយ ថវិកាវិនិយោគដោយប្រភពទុនក្នុងស្រុក | ៦០% |
| ៣២,២: បន្តបញ្ចូលចំណូល-ចំណាយដែលនៅក្រៅបរិបថ ថវិកាទៅក្នុងថវិកាប្រចាំឆ្នាំ ដោយរួមទាំងការកើនឡើងនូវ ការ ដាក់បញ្ចូលមូលនិធិមកពី ដៃគូអភិវឌ្ឍន៍ ទៅក្នុងថវិកា ប្រចាំឆ្នាំ | |
| • ក្រុមការងារបានចាប់ផ្តើមប្រមូលបទដ្ឋានគតិយុត្តិពាក់ព័ន្ធនឹងការគ្រប់គ្រង និង ដំណើរការរបស់គ្រឹះស្ថានសាធារណៈ ដើម្បីសិក្សា សម្រាប់រៀបចំថវិកាឧបសម្ព័ន្ធហើយធ្វើសមាហរណកម្ម ទៅក្នុងការរៀបចំថវិកាប្រចាំឆ្នាំ<br>• ក្រុមការងារបាន និង កំពុងត្រួតពិនិត្យសារាចរណែនាំបច្ចេកទេសរៀបចំថវិកាប្រចាំឆ្នាំ ដើម្បីកែលម្អតារាងរៀបចំថវិកាប្រចាំឆ្នាំ ក្នុងន័យធ្វើសមាហរណកម្មថវិការបស់គ្រឹះស្ថានសាធារណៈទៅក្នុងការរៀបចំថវិកាប្រចាំឆ្នាំ<br>• បានរៀបចំសេចក្តីព្រាងគំរូរបាយការណ៍ចំណូល-ចំណាយដែលអនុវត្តក្រៅបរិបថថវិកា | ១០% |
| **ក្រុមអនុវត្តថវិកា** | |
| ១៣.១ បន្តប្រមូលផ្តុំគណនី ធនាគាររបស់រដ្ឋាភិបាល និង ពង្រឹងគណនីទោលរបស់រតនាគារ | |
| - នៅដើមឆ្នាំ ២០០៩ មានគណនីចរន្តដែលមិនទាន់បានបង្កកចំនួន ១៧៤=១៨៧ (ដើមឆ្នាំ ២០០៨)-៤២ (បង្កកឆ្នាំ ២០០៨ នៅថ្នាក់កណ្តាល)+ ២៩ (នៅខេត្ត-ក្រុង បាននើកគណនីថ្មីចំនួន ២៩) | ២៤% |

| | |
|---|---|
| - បានបង្កកគណនីចរន្តចំនួន ៣៣ ក្នុងនោះបានបង្កកនៅ FTB ចំនួន ២២ និង NBC ចំនួន ១១<br>- បានផ្ទេរចេញ និងលុបចោលចំនួន ១៧ គណនី<br>- *ពិនិត្យឡើងវិញសំណើសុំបើកគណនីដែលត្រូវបានបិទៈ តាមចំណារបស់ឯកឧត្តមអគ្គលេខាធិការរង និង ជាប្រធានក្រុម អនុវត្តថវិកា*<br>- គណនីរបស់អគ្គនាយកដ្ឋានពន្ធដារ និងគណនីរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមានសមតុល្យសូន្យ នៅរៀងរាល់ចុងថ្ងៃ<br>- *សហការ និងពិនិត្យឡើងវិញនូវរាល់គណនីទាំងឡាយដែលមានការពាក់ព័ន្ធដើម្បីអោយប្រាកដថាជាគណនីក្រៅតំរោង* | |
| ១៣.២ បន្តពង្រីកការប្រើប្រាស់ ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល និងចំណាយ សាធារណៈ | |
| - ពង្រឹងបន្ថែមការប្រើប្រាស់សេវាធនាគារជាតិនៃកម្ពុជា ទាំងថ្នាក់កណ្តាល និងថ្នាក់ក្រោមជាតិ<br>- *សហការ និងចូលរួមជ្រើសរើសកំណត់ធនាគារពាណិជ្ជដែលមានបណ្តាញដល់ខេត្តក្រុង*<br>- បានប្រជុំពិភាក្សាលើយន្តការប្រើប្រាស់សេវាធនាគារពាណិជ្ជជាមួយជំនាញការគ្រប់គ្រងសាច់ប្រាក់លោក John Gardner<br>- មានក្រសួង-ស្ថាប័នចំនួន ០២ បានប្រើប្រាស់ធនាគារ ANZ សម្រាប់បើកប្រាក់បៀវត្ស<br>- *ចុះសិក្សា និងស្វែងយល់ការប្រើប្រាស់ប្រព័ន្ធធនាគារនៅរតនាគារជាតិ ធនាគារជាតិ ធនាគារអេស៊ីលីដា ធនាគារសាធារណៈ ធនាគារកាណាឌីយ៉ា មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សាខាពន្ធដារខេត្ត សាខាគយ និងរដ្ឋាករខេត្ត ទីចាត់ការគយ និងរដ្ឋាករប៉ោយប៉ែត រតនាគារខេត្ត មន្ទីរអប់រំ យុវជន និងកីឡា*<br>- *ចូលរួមពិភាក្សា និងស្តាប់ការធ្វើបទបង្ហាញរបស់ធនាគារពាណិជ្ជ*<br>- បានជ្រើសរើសយកធនាគារ អេស៊ីលីដា ធ្វើជាដៃគូរ ក្នុងការអនុវត្តសាកល្បងនៅខេត្តចំនួន ២ គឺខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល សម្រាប់ប្រតិបត្តិការចំណូល-ចំណាយ នៅក្នុងឆមាសទី២ ឆ្នាំ ២០០៩<br>- បាន និងកំពុងពិនិត្យលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា រវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ធនាគារ អេស៊ីលីដា ភីអិលស៊ី<br>- បានជំរុញក្រសួង-ស្ថាប័ន ឱ្យប្រើប្រាស់សេវាធនាគារ ANZ ក្នុងការបើកប្រាក់បៀវត្សជូនមន្ត្រីរាជការ<br>- *ចូលរួមកំណត់ជ្រើសរើសធនាគារអេស៊ីលីដាដែលមានបណ្តាញសាខាខេត្ត-ក្រុង ស្រុក និងឃុំ*<br>- *ពិនិត្យសេចក្តីព្រាង MOU លើកទី ១*<br>- ក្រោយពេលដែលការអនុវត្តសាកល្បងនៅខេត្តចំនួន ២ គឺខេត្តបន្ទាយមានជ័យ និងខេត្តកណ្តាល សម្រាប់ប្រតិបត្តិការ ចំណូល-ចំណាយ | ៤៨% |

| | |
|---|---|
| បានទទួលជោគជ័យនោះនឹងបន្តពង្រីកទៅខេត្តចំនួន ០៥ ទៀត | |
| ១៣.៣ ប្រមូលផ្តុំនិងបន្តកែលម្អ ផែនការសាច់ប្រាក់(ចាប់ផ្តើមពី ប្រចាំត្រីមាស / ប្រចាំខែ និង ចាប់ផ្តើមជាបណ្តើរៗទៅប្រចាំសប្តាហ៍ និង ប្រចាំថ្ងៃ | |
| - *រៀបចំចងក្រងតារាងចំណាយតាមក្រសួង តាមជំពូកបញ្ជូលទិន្នន័យឆ្នាំ ២០០៧ និងធ្វើបច្ចុប្បន្នភាពទិន្នន័យឆ្នាំ ២០០៨* | *១៥%* |
| - *រៀបចំចងក្រងតារាងចំណូលតាមក្រសួង និងនាយកដ្ឋានចំណូល តាមគណនី និងអនុគណនីបញ្ចូលគណនីឆ្នាំ ២០០៧ និងធ្វើបច្ចុប្បន្នភាពទិន្នន័យឆ្នាំ ២០០៨* | |
| - *ធ្វើលិខិតជូននាយកដ្ឋានពាក់ព័ន្ធស្នើសុំមន្ត្រីពាក់ព័ន្ធក្នុងក្រុមការងារបច្ចេកទេសផ្ទៃក្នុងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ* | *១៥%* |
| - *ធ្វើលិខិតស្នើសុំរបាយការណ៍ និងសហការពីនាយកដ្ឋានថវិកា* | |
| - *រៀបចំគំរូរបាយការណ៍ស្តីពីស្ថានភាពសាច់ប្រាក់រដ្ឋ* | *១៥%* |
| - *ចាត់តាំងមន្ត្រីចូលរួមក្នុងក្រុមការងារប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុតាមព័ត៌មានវិទ្យា* | |
| - *កំណត់ និងពិភាក្សាជាមួយជំនាញការពីការកំណត់ទម្រង់ និងរៀបចំម៉ូដែលសម្រាប់ការព្យាករណ៍លំហូរសាច់ប្រាក់* | |
| - *ដាក់រូបមន្តធ្វើការសាកល្បងម៉ូដែល និងដាក់ជូនជំនាញការគ្រប់គ្រងសាច់ប្រាក់ពិនិត្យ និងកែសម្រួលរូបមន្តក្នុងម៉ូដែល* | |
| - *រៀបចំ ចងក្រងតារាងចំណូលតាមក្រសួង និងនាយកដ្ឋានចំណូល តាមគណនី ២០០៧ និង ២០០៨* | |
| - *សិក្សាពីការវិវត្តន៍នៃចំណាយមូលធន ២០០៧ និង ២០០៨* | |
| - *រៀបចំចងក្រងតារាងចំណាយចរន្តតាមក្រសួង តាមជំពូកបញ្ជូលទិន្នន័យឆ្នាំ ២០០៧ និងធ្វើបច្ចុប្បន្នភាពទិន្នន័យឆ្នាំ ២០០៨* | |
| - *សិក្សាពីការវិវត្តន៍នៃចំណាយ ២០០៧ និង ២០០៨* | |
| - *រៀបចំចងក្រងតារាងចំណាយមូលធនតាមក្រសួង តាមជំពូកបញ្ជូលទិន្នន័យឆ្នាំ ២០០៧ និងធ្វើបច្ចុប្បន្នភាពទិន្នន័យឆ្នាំ ២០០៨* | |
| - *សិក្សាពីការវិវត្តន៍នៃចំណាយមូលធន ២០០៧ និង ២០០៨* | |
| - *មានតួលេខនៅឆ្នាំចាស់ ប៉ុន្តែពុំមានក្នុងច្បាប់ថវិកាឆ្នាំ ២០០៩* | |
| - *ចំណូល-ចំណាយមួយចំនួនមានសញ្ញាអវិជ្ជមាន ព្រោះដោយសារការធ្វើនិយ័ត* | |
| - *បានសិក្សា និងពិភាក្សាជាមួយជំនាញការ ដើម្បីធ្វើសេចក្តីព្រាងលិខិតសុំការសហការជាមួយស្ថាប័នពាក់ព័ន្ធ* | |
| - *បានធ្វើសេចក្តីព្រាងលិខិតសុំការសហការជាមួយស្ថាប័នពាក់ព័ន្ធ* | |

| | |
|---|---|
| - *កំពុងសិក្សាលើម៉ូដែលដែលកំពុងរៀបចំដើម្បីស្វែងរកទូវកំហុសឆ្គងដែលកើតមានចំពោះស្ថាប័នមួយចំនួន*<br>- *រៀបចំតារាងគំរូព្យាករណ៍ប្រចាំខែ*<br>- *បង្កើតតារាងប្រៀបធៀបរវាងផែនការ និងការអនុវត្តជាក់ស្តែង*<br>- *សហការស្រាវជ្រាវជាមួយរតនាគារដើម្បីកំណត់កម្រិតការការពារសាច់ប្រាក់សមស្របនៅគណនីទោលរតនាគារដើម្បីធានាលំហូរសាច់ប្រាក់រដ្ឋាភិបាល*<br>- *របាយការណ៍ស្តីពីសមតុល្យសាច់ប្រាក់រដ្ឋប្រចាំសប្តាហ៍*<br>- *របាយការណ៍ស្តីពីសមតុល្យសាច់ប្រាក់រដ្ឋប្រចាំថ្ងៃ* | |
| ១៣.៤ បន្តតាមដានបំណុល កកស្ទះ និង អាយុកាលរបស់វា | |
| - ចាប់តាំងពីឆ្នាំ ២០០៧ មកពុំមានបំណុលកកស្ទះទេ នៅអគ្គនាយកដ្ឋានរតនគារជាតិ<br>- បានកំណត់វិធាននៃបំណុលទៅតាមអាទិភាពដែលរួមមានប្រាក់បៀវត្ស-ការប្រាក់-ប្រាក់ដើម-ថវិកាតាមកម្មវិធី-បេសកកម្ម-ក្រុមហ៊ុន | *១០០%* |
| ១៤.១ កែលម្អក្របខ័ណ្ឌច្បាប់លទ្ធកម្មសាធារណៈ | |
| - បានពិនិត្យកែលម្អបន្ថែមលើឧបសម្ព័ន្ធ (Annex) នៃ IRRPP<br>- បានពិនិត្យផែនការលទ្ធកម្មរបស់ស្ថាប័នចំណាយ ដើម្បីដាក់ជូនថ្នាក់ដឹកនាំ កសហវ ពិនិត្យ-សម្រេច<br>- បានប្រជុំផ្ទៃក្នុងនាយកដ្ឋានដើម្បីពិនិត្យសេចក្តីព្រាងច្បាប់លទ្ធកម្មបឋម | ៤០% |
| ១៤.៤ ពង្រឹងសមត្ថភាពនាយក ដ្ឋានលទ្ធកម្មសាធារណៈដើម្បី ត្រួតពិនិត្យតាមដាន និងវាយ តម្លៃសមិទ្ធកម្មនៃប្រព័ន្ធលទ្ធកម្ម សាធារណៈ | |
| - បានប្រជុំពិភាក្សាជាមួយ IPA (Crown Agent) ដើម្បីស្វែងរកលទ្ធភាពជ្រើសរើសទីប្រឹក្សាអន្តរជាតិឱ្យបានឆាប់<br>- បានប្រមូល និងវិភាគរបាយការណ៍លទ្ធកម្មរបស់ស្ថាប័នចំណាយ<br>- បានចុះធ្វើសវនកម្មកិច្ចលទ្ធកម្មជាក្រោយទៅលើក្រសួងអទិភាពចំនួន ០៤ គឺ: ក្រសួងអប់រំ យុវជន និងកីឡា, ក្រសួងសុខាភិបាល, ក្រសួងកសិកម្ម និងក្រសួងអភិវឌ្ឍន៍ជនបទ<br>- បានពិភាក្សាលើការរៀបចំបង្កើតការិយាល័យផែនការលទ្ធកម្មសាធារណៈ<br>- បានបញ្ជូនមន្ត្រីទទួលបន្ទុកការងារ FMIS ទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីអំពី:(១) គណនេយ្យរដ្ឋាភិបាល និងក្របខ័ណ្ឌគ្រប់គ្រងការកែទម្រង់ | ២៥% |

| | |
|---|---|
| ហិរញ្ញវត្ថុសាធារណៈ (២) គំរូនៃការត្រួតពិនិត្យឡើងវិញលើ Business Process រៀបចំដោយនាយកដ្ឋានព័ត៌មានវិទ្យារបស់ កសហវ | |
| ១៤.៥ បង្កើនភាពប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការ លទ្ធកម្មតាមរយៈការបង្កើនការ ផ្សព្វផ្សាយជាសាធារណៈ និង ដោយចំហរ | |
| - បានប្រជុំពិភាក្សាជាមួយទីប្រឹក្សាក្នុងស្រុកអំពីការងារលំអិតដែលត្រូវរៀបចំបង្កើតគេហទំព័រលទ្ធកម្ម និងពិភាក្សាលើសេចក្តីព្រាងនៃកិច្ចសន្យា រវាងឯកឧត្តមប្រធាន PFM និងទីប្រឹក្សាក្នុងស្រុក។ | |
| ២១.៦ កែសម្រួលរចនាសម្ព័ន្ធ ស្ថាប័នឱ្យឆ្លើយតបទៅនឹងប្រព័ន្ធ ដំណើរការការងារថ្មីដែលត្រូវបានបង្កើតរួមទាំងការបន្តបញ្ជូន មន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ទៅតាមក្រសួង-ស្ថាប័ន ដោយកំណត់ ឱ្យបានច្បាស់ពីតួនាទីនៅក្នុង ក្របខ័ណ្ឌវិមជ្ឈការ | |
| - ការិយាល័យជំនាញទទួលបន្ទុកសកម្មភាពរៀបចំ និងចាត់បញ្ជូនក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុទៅប្រចាំក្រសួង-ស្ថាប័ន ចំនួន១១ កំពុងត្រៀមរៀបចំព្រាងលិខិតផ្ញើជូនក្រសួង-ស្ថាប័នពាក់ព័ន្ធស្តីពីការចាត់បញ្ជូនក្រុមមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ទៅអមនៅតាមក្រសួងស្ថាប័នផ្ទាល់ | ចាប់ផ្តើម |
| ២៣.១ ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនីថ្មី និង ចំណាត់ថ្នាក់ថវិកាថ្មីដើម្បីពង្រឹង នឹងអនុវត្តជាបណ្តើរៗ ចំណាត់ ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | |
| - បានបន្តធ្វើសមាហរណកម្មបំណុលត្រូវទារ ជាមួយអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋករកម្ពុជា និងបំណុលត្រូវសងជាមួយនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ<br>- បន្តរធ្វើការប្រមូលទិន្នន័យដើម្បីធ្វើការកត់ត្រាបំណុលប្រាក់ខ្ចី និងបំណុលប្រាក់ត្រូវទារ<br>- បន្តចូលរួមធ្វើការចំលងលេខកូដបន្ទឹមគ្នា (Bridge Table) រវាងប្លង់គណនិថ្មី និងតារាង TOFE ជាមួយនាយកដ្ឋាន គោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ ក្រោមការដឹកនាំផ្ទាល់ពីជំនាញការ IMF<br>- បន្តចូលរួមពិភាក្សាជាមួយក្រុមបេសកកម្មជំនួយបច្ចេកទេស មកពី IMF លោក John Gardner លោក Mark Saline និងលោកស្រី Gisel-Suir ក្នុងការពង្រីកវិសាលភាពការប្រើប្រាស់ ធនាគារពាណិជ្ជ ការរៀបចំចំណាត់ថ្នាក់ថវិកា និង ចំណាត់ថ្នាក់គណនីតាមមុខងារ និងតាមកម្មវិធី | |
| ២៣.៣ សិក្សា និងផ្តល់ ជម្រើសសម្រាប់ការឈានទៅ ប្រព័ន្ធគណនេយ្យបង្គរជា ជំហានៗ | |
| - បានធ្វើសមាហរណកម្មបំណុលត្រូវសង និងត្រូវទារជាមួយ DIC<br>- បានធ្វើសមាហរណកម្មបំណុលត្រូវទារជាមួយអគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា<br>- បានប្រជុំជាមួយនាយកដ្ឋានទ្រព្យរដ្ឋ<br>- បានផ្ញើរលិខិតជូននាយកដ្ឋានចំណូលមិនមែនសារពើពន្ធរួចហើយ តែមិនទាន់បានទទួលចំលើយតបវិញនៅឡើយ | |

| | |
|---|---|
| ២៣.៤ រៀបចំ និងផ្សព្វផ្សាយ ឯកសារណែនាំអំពីគណនេយ្យ | |
| - បានរៀបចំ និងប្រម៉ែប្រមូលរាល់ប្រកាសណែនាំ សារាចរណែនាំ សេចក្តីណែនាំ<br>- បានប្រជុំពិភាក្សាជាមួយ DIC និងនាយកដ្ឋានថវិកា<br>- បានធ្វើការបំបែកឥណទានជាពីរៈ ឥណទានវិនិយោគ និងឥណទានចរន្ត | |
| ២៤.១ បន្តកាត់បន្ថយពេលវេលា សម្រាប់ការស្នើសុំធានាចំណាយ និងការទូទាត់ នៅក្នុងក្រសួង-ស្ថាប័ន ។(*ដោយសន្មតថាមានការកែលម្អ ទៅលើប្រព័ន្ធដែលកំពុងអនុវត្ត និងការចាប់ផ្តើមអនុវត្តជា បណ្តើរៗ* FMIS *នៅក្នុងឆ្នាំ ២០០៩ និង ២០១០*) | |
| - បានធ្វើការកាត់បន្ថយបរិបទការងារនិងពន្លឿនក្នុងការពិនិត្យលិខិតយុត្តិការភ្ជាប់តាមអាណត្តិបើកប្រាក់ និងការទូទាត់ | |
| ២៤.២ កែលម្អដំណើរការនៃ ប្រតិបត្តិការនៅក្នុង កសហវ/ ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្រប ទៅនិងការវិវឌ្ឍន៍នៃប្លង់ គណនេយ្យ និងបទដ្ឋាន គណនេយ្យ ព្រមទាំងធ្វើការ ផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | |
| - នាយកដ្ឋានហិរញ្ញកិច្ច និងនាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ បានធ្វើរួចរាល់ហើយនូវសេចក្តីព្រាងអនុក្រិត្យស្តីពីការកែលម្អនីតិវិធីចំណាយថវិកាចរន្ត និងចំណាយថវិកាវិនិយោគសម្រាប់ថវិកាបុរេប្រទាន។ សេចក្តីព្រាងនេះ នឹងដាក់ជូនអង្គប្រជុំជាថ្មីម្តងទៀតដើម្បីពិនិត្យ និងសម្រេចជាចុងក្រោយ។<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីរជ្ជទេយ្យបុរេប្រទាន-រជ្ជទេយ្យចំណូល និងប្រាក់បុរេប្រទានសម្រាប់ក្រសួង-ស្ថាប័នថ្នាក់ កណ្តាល<br>- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការបិទបញ្ជីឆ្នាំ ២០០៨ បន្ថែម និងនីតិវិធីនៃការកត់ត្រារជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យចំណូលដល់រតនាគារខេត្ត-ក្រុង និងទីប្រឹក្សាហិរញ្ញវត្ថុថ្នាក់មូលដ្ឋាន<br>- បានរៀបចំវគ្គបណ្តុះបណ្តាលរជ្ជទេយ្យបុរេប្រទាន រជ្ជទេយ្យចំណូលដោយឡែកជាមួយក្រសួងអប់រំ យុវជន និងកីឡា<br>- បន្តការរៀបចំតាក់តែងឯកសារគណនេយ្យ សម្រាប់ធ្វើការតាមដានកត់ត្រារជ្ជទេយ្យបុរេប្រទាន និងរជ្ជទេយ្យចំណូល<br>- បានធ្វើការផ្ទូផ្ទងគណនីធនាគារជាប្រចាំ | ៩០% |
| ២៥.១ ពិនិត្យឡើងវិញនូវ ស្តង់ដារគណនេយ្យរដ្ឋបាល សាធារណៈដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAAP) និង វាយតម្លៃភាពប្រាកដនិយម និងភាពសមស្របនៃលំដាប់ លំដោយក្នុងការដាក់ឱ្យអនុវត្ត ស្តង់ដារគណនេយ្យនេះដោយ ផ្សារភ្ជាប់ទៅនឹងការពង្រីកការ ប្រើប្រាស់ FMIS | |
| - បានរៀបចំធ្វើរបាយការណ៍ប្រចាំឆ្នាំស្តីពីចំនួនអាណត្តិ និងតួលេខសរុបដែលទទួលបានក្រោយថ្ងៃ ៣១ ខែ ធ្នូ នេះរួចហើយ | |

| | |
|---|---|
| -   បានណែនាំដោយក្រសួង-ស្ថាប័ន  ធ្វើការបោះផ្សាយអាណត្តិបើកប្រាក់ស្របតាមកម្មវិធីដែលនាយកដ្ឋានថវិកាផ្តល់ជូន | |
| **ក្រុមគោលនយោបាយ** | |
| ១១.១.  កែសម្រួល  និងអនុវត្តគោលនយោបាយ  ចំណូលរយៈពេលមធ្យម | |
| ធ្វើបច្ចុប្បន្នភាពគោលនយោបាយចំណូល | ៨0% |
| ១១.៣.បន្តកែលម្អរដ្ឋបាល  និង  គោលនយោបាយពន្ធ  គយ  (រួមទាំងវិធានការ  កែលម្អការផ្តល់ព័ត៌មាន  និងតម្លាភាពដល់អ្នកបង់ពន្ធ  និងអ្នកបង់កម្រៃសេវា) | |
| បានពិនិត្យកិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន, កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន-ចិន, កិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ាន- កូរ៉េ, ការសន្យារបស់កម្ពុជានៅក្រោមក្របខ័ណ្ឌតំបន់ពាណិជ្ជកម្មសេរី,  កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញរវាង សមាជិកអាស៊ាន, អាស៊ាន-ចិន, អាស៊ាន-កូរ៉េ | ៩0% |
| ១១.៤.បន្តកែលម្អរដ្ឋបាល  និង  គោលនយោបាយ  ពន្ធដារ | |
| ធ្វើបច្ចុប្បន្នភាពគោលនយោបាយចំណូល | ៨0% |
| ១១.៥.  បន្តកែលម្អគោល  នយោបាយ  និងរដ្ឋបាល  ចំណូលមិនមែនសារពើពន្ធ  រួមទាំងទ្រព្យសម្បត្តិរដ្ឋ | |
| ធ្វើបច្ចុប្បន្នភាពគោលនយោបាយចំណូល | ៨0% |
| ១១.៦.ពង្រឹងការព្យាករណ៍  ម៉ាក្រូសេដ្ឋកិច្ច  និង  ការព្យាករណ៍ចំណូល | |
| ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌម៉ាក្រូសេដ្ឋកិច្ច | ៨0% |
| ២១.១.ពិនិត្យឡើងវិញ  និងធ្វើវិសោធនកម្មលើ  ច្បាប់  និងបទបញ្ញត្តិដែលកំណត់  ពីតួនាទី  និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រដ្ឋាភិបាល | |
| បានទទួលការឯកភាពពីថ្នាក់ដឹកនាំឱ្យរៀបចំសារាចរណែនាំនេះ | ៨0% |
| រង់ចាំការអញ្ជើញចូលរួមពីនាយកដ្ឋានសាមី | ១0% |
| កំពុងដំណើរការស្រាវជ្រាវ ចងក្រង និងសិក្សា | ២0% |

| | |
|---|---|
| ២២.១. បង្កើតឱ្យមាន ទណ្ឌកម្ម សមស្របចំពោះ កំហុសឆ្គងឬ ការគ្រប់គ្រង ធនធានសាធារណៈ មិនសមស្រប និងគ្មាន ប្រសិទ្ធភាព ។ ទណ្ឌកម្មនេះត្រូវចែងនៅ ក្នុងច្បាប់ និងធ្វើការផ្សព្វផ្សាយនិង ណែនាំឱ្យ បានទូលំទូលាយ | |
| បាន និង កំពុងផ្តោតការយកចិត្តទុកដាក់លើការស្នើសុំអ្នកជំនាញការពីប្រទេសបារាំង និង ស្នើសុំអ្នកជំនួយការក្នុងស្រុក ព្រមទាំងការស្នើសុំធ្វើ ទស្សនកិច្ចសិក្សានៅប្រទេសមួយចំនួនដូចជា ប្រទេសបារាំង ឬ ជប៉ុន ឬ វៀតណាម ក្នុងគោលបំណងរៀបចំបង្កើតស្តង់ដារអធិការកិច្ចហិរញ្ញវត្ថុរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុឱ្យបានសម្រេចក្នុង ដំណាក់កាលទី ២ នៃ PFMRP នេះ ។<br>បន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការផ្សព្វផ្សាយវិន័យទាំង ១០ ប្រការ របស់រាជរដ្ឋាភិបាលក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនដល់ក្រសួង-ស្ថាប័ន មន្ទីរជំនាញរាជ ធានី-ខេត្ត និង សហគ្រាសសាធារណៈ ។<br>បានរៀបចំរួចរាល់នូវកម្មវិធីនៃកិច្ចប្រតិបត្តិការអធិការកិច្ចហិរញ្ញវត្ថុឆ្នាំ ២០០៩ សម្រាប់ធ្វើការត្រួតពិនិត្យការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈក្នុងការិយបរិច្ឆេទឆ្នាំ ២០០៨ និង បានដាក់ជូន ថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សម្រេច ។ | |
| កំពុងដំណើរការចូលរួមប្រជុំពិគ្រោះ និងផ្តល់យោបល់ច្បាប់ | ៧០ % |
| កំពុងដំណើរការកសាងមូលដ្ឋានទិន្នន័យច្បាប់ | ១០ % |
| ២៣.១. ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនីថ្មី និង ចំណាត់ថ្នាក់ថវិកាថ្មីដើម្បីពង្រឹង នឹងអនុវត្តជាបណ្តើរ១ ចំណាត់ ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | |
| រៀបចំ និងធ្វើបច្ចុប្បន្នភាព TOFE និង GFS ខែមករា-កុម្ភៈ ២០០៩ | ៨០% |
| ២៤.៣. បង្កើនកម្រិតយល់ដឹង ភាពជាម្ចាស់ ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ | |
| - បន្តការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាផ្នែកវិភាគនីតិវិធីអនុវត្តការងារ (Business analyst) ចំនួន ១០ រូប | ២០% |
| - បានបណ្តុះបណ្តាលមន្ត្រីជំនាញផ្នែកព័ត៌មានវិទ្យាចំនួន ១៤ រូប លើផ្នែកព័ត៌មានវិទ្យាជាមូលដ្ឋានចំនួន ០២ វគ្គសិក្សា រួមមានៈ<br>១-កម្មវិធី ប្រតិបត្តិការបើកទូលាយ Linux Red Hat ថ្នាក់មូលដ្ឋាន និង<br>២-កម្មវិធីប្រតិបត្តិការបើកទូលាយ Linux Red Hat កម្រិតជំនាញ និង បន្ត រៀបចំចូលរួមក្នុងវគ្គបណ្តុះបណ្តាលជាមូលដ្ឋានចំនួន ០៤<br>ទៀតលើកម្មវិធីគ្រប់គ្រងមូលដ្ឋាន ទិន្នន័យ Oracle 11*g* និង Microsoft SQL Server 2008 | ២៥% |
| - បណ្តុះបណ្តាលមន្ត្រីសមាជិកក្រុមការងារអនុវត្តគម្រោង GFMIS ចំនួន ១១០ រូបលើជំនាញផ្នែកនីតិវិធីអនុវត្តការងារ រួមមាន | ២០% |

| | |
|---|---|
| ១-គណនេយ្យរដ្ឋាភិបាល (កម្រិតខ្ពស់) និង ក្របខ័ណ្ឌគ្រប់គ្រងការកែទម្រង់ហិរញ្ញវត្ថុសាធារណៈមួយល្អប្រសើរ<br>២-ការពិនិត្យមើល ឡើងវិញលើគំរូនៃ Business Process | |
| ២៤.៥. ពង្រឹងការរៀបចំ FMIS និងបញ្ចប់ដំណើរការលទ្ធកម្ម | |
| បញ្ជូនឯកសាងឯកសារដេញថ្លៃសម្រាប់ដំណាក់កាលទី ២ ដល់ធនាគារពិភពលោកដើម្បីពិនិត្យមើល និង ផ្តល់ No Objection Letter | ៨០% |
| បានប្រមូលចងក្រងជាឯកសារមុខងារ តួនាទី លិខិតបទដ្ឋានរបស់នាយកដ្ឋានទាំងអស់នៅក្នុងក្រសួង ស.ហ.វ ដើម្បីចងក្រង ជាឯកសារ នីតិវិធីអនុវត្តការងាររួម ដែលមានស្រាប់ ជាមួយនឹងការរៀបចំវគ្គបណ្តុះបណ្តាលថ្មីៗជាបន្តបន្ទាប់ | ២២% |
| ២៤.៦.រៀបចំផែនការ អនុវត្តរួម (ការសាកល្បង និងការពង្រីក) ដោយរួមបញ្ចូល កសហវ ក្រសួង-ស្ថាប័ននិងអង្គភាព ថ្នាក់ក្រោមជាតិ | |
| រៀបចំការធ្វើអង្កេតដើម្បីវាយតម្លៃមើលលើភាពត្រៀមជាស្រេចក្នុងការផ្លាស់ប្តូរនៅគ្រប់នាយកដ្ឋាន ក្រសួង-ស្ថាប័ន | ៣២% |
| ២៤.៨.ការអនុវត្តសាក ល្បង ជំហានដំបូង និងពង្រីកការ អនុវត្ត FMIS (ម៉ូឌុលស្នូល និង ម៉ូឌុលសម្រាប់ថវិកា) | |
| មន្ត្រីអគ្គាធិការដ្ឋានបានបំពេញកម្រងសំណួរទាក់ទងនឹងផ្នែកព័ត៌មានវិទ្យារបស់ នាយកដ្ឋាន ព័ត៌មានវិទ្យាដោយផ្តោតលើ : សមត្ថភាពមន្ត្រីដែលអាចប្រើប្រាស់កុំព្យូទ័របាន , កម្មវិធីដែលអាចប្រើប្រាស់បាន , តម្រូវការរបស់អគ្គាធិការដ្ឋាន និងចំនួនមន្ត្រីដែលមានការ ចាប់អារម្មណ៍លើវគ្គបណ្តុះបណ្តាលផ្នែកព័ត៌មានវិទ្យា ។ | |
| ២៥.១.ពិនិត្យឡើងវិញនូវ ស្តង់ដារគណនេយ្យរដ្ឋបាល សាធារណៈដែលមាន លក្ខណៈ ជា អន្តរជាតិ (IPSAS, GAAP) និង វាយតម្លៃភាពប្រាកដ និយមនិងភាពសមស្រប នៃលំដាប់លំដោយ ក្នុងការដាក់ឱ្យអនុវត្ត ស្តង់ដារគណនេយ្យនេះ ដោយផ្សារភ្ជាប់ទៅនឹងការ ពង្រីកការប្រើប្រាស់ FMIS | |
| ចូលរួមជាមួយនាយកដ្ឋានព័ត៌មានវិទ្យា និងបណ្តុះបណ្តាលមន្ត្រីអំពី FMIS | ១០% |
| ២៥.២.ដាក់ឱ្យអនុវត្តនូវ របាយការណ៍អនុវត្តថវិកា ប្រចាំត្រីមាសដែលបញ្ជាក់ អំពីការងារ ដែលបាន បំពេញធៀបនិងគោលដៅ លទ្ធផលទទួលបាន ការយឺតយ៉ាវនិង វិធានការ ដោះស្រាយ : ពីក្រសួង-ស្ថាប័នមក កសហវ និង នៅផ្ទៃក្នុងក្រសួង-ស្ថាប័ន ពី អង្គភាពថវិការហូតដល់ ថ្នាក់ដឹកនាំ | |
| ចូលរួមជាមួយនាយកដ្ឋានព័ត៌មានវិទ្យា និងបណ្តុះបណ្តាលមន្ត្រីអំពី FMIS | ១០% |
| ២៥.៤.កែលម្អទម្រង់ របាយការណ៍និងការផ្លាស់ ប្តូរព័ត៏មានជាមួយ សាធារណៈជន | |
| ចូលរួមជាមួយនាយកដ្ឋានព័ត៌មានវិទ្យា និងបណ្តុះបណ្តាលមន្ត្រីអំពី FMIS | ១០% |
| ២៦.២. កែលម្អយន្តការដើម្បី ធានាការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពទៅនឹងលទ្ធផល សវនកម្ម និងអធិការកិច្ចនៅ តាមបណ្តាអង្គភាពថវិកា | |

| | |
|---|---|
| បានចុះបំពេញការងារធ្វើអធិការកិច្ចហិរញ្ញវត្ថុដើម្បីចូលរួមបង្កើនគណនេយ្យភាពនៅគ្រប់លំដាប់ថ្នាក់នៃការអនុវត្តថវិកានៅក្រសួងរដ្ឋបាលកណ្តាលចំនួន ០៥ ,មន្ទីរជំនាញជុំវិញខេត្តចំនួន ១៧ និង សហគ្រាសសាធារណៈចំនួន ០៣ ។ | |
| បានចុះធ្វើការស៊ើបអង្កេតស្រាវជ្រាវលើករណីពាក្យបណ្តឹងរបស់សមាគមដឹកជញ្ជូនទំនិញផ្លូវគោកកម្ពុជា ប្តឹងអ្នកម៉ៅការប្រមូលភាស៊ីចំណតរថយន្តនិង កំពង់ផែជលយានយន្តនៅខណ្ឌមិត្តភាព ខេត្តព្រះសីហនុ ។ | |
| ២៦.៣.រៀបចំនិងកែលម្អ ផែនការសវនកម្ម/អធិការកិច្ច ប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ វាយតម្លៃហានិភ័យដែលបាន ផ្តល់អនុសាសន៍ដោយកសហវ | |
| -ក្រុមការងាររបស់អគ្គាធិការដ្ឋានបានរៀបចំ និង ពិនិត្យការធ្វើផែនការរយៈពេលបីឆ្នាំ ដោយផ្អែកលើការវាយតម្លៃហានិភ័យដែលបានណែនាំដោយថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។<br>-បាន និង កំពុងបន្តចូលរួមផ្តល់យោបល់ជាអនុសាសន៍ ក្នុងការបែងចែកតួនាទី និង ភារកិច្ចរវាងអធិការកិច្ច និង សវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួងស្ថាប័ន ដែលនៅមានបញ្ហាលើការអនុវត្ត ។ | |
| ២៦.៤. កសហវ ពិនិត្យមើល ឡើងវិញ ពីភាពគ្រប់គ្រាន់នៃគំរូ របាយការណ៍សវនកម្ម/ អធិការកិច្ច | |
| -បានធ្វើការត្រួតពិនិត្យឡើងវិញនូវរាល់បណ្តាសំណូមពរ ឬ អនុសាសន៍បានលើកឡើងនាពេលចុះបំពេញការងារធ្វើអធិការកិច្ចហិរញ្ញវត្ថុ នៅក្រសួង រដ្ឋបាលកណ្តាលចំនួន ០៥ , មន្ទីរជំនាញជុំវិញខេត្តចំនួន ១៧ និង សហគ្រាសសាធារណៈចំនួន ០៣ ។<br>-គណៈប្រតិភូអធិការកិច្ចហិរញ្ញវត្ថុ ០២ ក្រុម បានចុះធ្វើអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រង និង ប្រើប្រាស់ថវិកាតាមកម្មវិធី ( PB) នៅខេត្តកោះកុង និង ខេត្តមណ្ឌលគិរី ។<br>- បានរៀបចំក្រុមការងាររបស់អគ្គាធិការដ្ឋានធ្វើសេចក្តីព្រាងប្រកាសស្តីពីវិន័យ ក្រមសីលធម៌ វិជ្ជាជីវៈជូនដល់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ<br>- បានរៀបចំក្រុមការងាររបស់អគ្គាធិការដ្ឋានសម្រាប់ធ្វើការត្រួតពិនិត្យ និង វាយតម្លៃជាប្រចាំ ការអនុវត្តភារកិច្ចរបស់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ<br>-បានចុះបំពេញការងារធ្វើអធិការកិច្ចលើការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនៅក្រសួងរដ្ឋបាលកណ្តាលចំនួន ០៥ , មន្ទីរជំនាញជុំវិញខេត្តចំនួន ១៧ និង សហគ្រាសសាធារណៈចំនួន ០៣ ។ | |
| ២៦.៥.កែលម្អរបាយការណ៍ សវនកម្ម/អធិការកិច្ច | |
| -ត្រៀមរៀបចំធ្វើលិខិតជម្រុញកែលំអលើចំណុចខ្វះខាតក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង កាតព្វកិច្ចត្រូវបង់ចំណូលចូលថវិការដ្ឋនាការិយ បរិច្ឆេទឆ្នាំ ២០០៧ ជូន ក្រសួង-ស្ថាប័ន , មន្ទីរជំនាញរាជធានី-ខេត្ត និង សហគ្រាសសាធារណៈដែលបានធ្វើអធិការកិច្ចហិរញ្ញវត្ថុក្នុងឆ្នាំ ២០០៨រួច ។<br>-បានរៀបចំសេចក្តីព្រាងរបាយការណ៍លទ្ធផលនៃការងារអធិការកិច្ចហិរញ្ញវត្ថុប្រចាំឆ្នាំ ២០០៨ និង កំពុងដាក់ជូនថ្នាក់ដឹកនាំអគ្គាធិការដ្ឋានពិនិត្យ និងសម្រេច ។<br>-ក្រុមការងាររបស់អគ្គាធិការដ្ឋានបានត្រៀមធ្វើការពិនិត្យឡើងវិញ ដើម្បីកែសម្រួលខ្លឹមសារមួយចំនួនលើសៀវភៅណែនាំស្តីពីនីតិវិធីនៃការធ្វើ អធិការកិច្ចហិរញ្ញវត្ថុ ឱ្យស្របគ្នាជាមួយការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី | |

| | |
|---|---|
| ២៨.១. រៀបចំស្ថាប័នដើម្បី ឆ្លើយតបនឹងដំណាក់កាលទី២ ដោយរួមមាន: ការបញ្ចប់ការ វិភាគមុខងារនៅគ្រប់ នាយកដ្ឋាននៃកសហវ និង នាយកដ្ឋាន ហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ។ រៀបចំ និង អនុវត្តផែនការ យុទ្ធសាស្ត្ររបស់នាយកដ្ឋាន នីមួយៗ ។ រៀបចំ និង ផ្សព្វផ្សាយឯកសារណែនាំស្តីពី ប្រព័ន្ធគ្រប់គ្រង។ រៀបចំគោលនយោបាយសម្រាប់ យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មាន វិទ្យានៅកសហវការកសាង សមត្ថភាពនាយកដ្ឋាន ការប្រើប្រាស់ជំនួយ បច្ចេកទេស ប្រកបដោយប្រសិទ្ធភាព ។ កែលម្អការអនុវត្តការងារ តាម រយៈការបង្កើនការប្រើប្រាស់ បច្ចេកវិទ្យា។ | |
| -បានធ្វើការកែសម្រួលលើផែនការបណ្តុះបណ្តាលជូនដល់មន្ត្រីអធិការកិច្ចហិរញ្ញវត្ថុ ពាក់ព័ន្ធនឹងពេលវេលានៃការបណ្តុះបណ្តាល និង បានបញ្ជូនផែនការកែសម្រួលថ្មី ផ្ញើជូនដល់វិទ្យាស្ថានសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង លេខាធិការដ្ឋានកំណែទម្រង់ ។<br>-អគ្គាធិការដ្ឋានបានចាត់បញ្ជូនតំណាងដើម្បីចូលរួមក្នុងអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការក្នុងការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ( លិខិតលេខ ០០៩ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ២០០៩ របស់អគ្គាធិការដ្ឋាន កសហវ ) ។ | |
| **៣២.១. រៀបចំគោល នយោបាយសម្រាប់ធ្វើ សមាហរណកមថវិកា ។ បន្ត កែលម្អការធ្វើសមាហរណកម្ម ថវិកាចរន្ត និងមូលធនតាម រយៈការបន្តអនុវត្តក្របខ័ណ្ឌ ចំណាយរយៈពេលមធ្យម ផែនការយុទ្ធសាស្ត្រថវិកា និងថិវកាតាមកម្មវិធី ។ ឆ្លុះ បញ្ចាំងទិដ្ឋភាពកាត់បន្ថយ ភាពក្រីក្រ និងយែនឌ័រទៅ ក្នុង គោលការណ៍ណែនាំស្តីពី ផែនាកាយុទ្ធសាស្ត្រថវិកា និងថវិកាតាមកម្មវិធី** | |
| ធ្វើបច្ចុប្បន្នភាពក្របខ័ណ្ឌចំណាយរយៈពេលមធ្យម MTEF | ៨០% |
| **ក្រុមគាំទ្រទូទៅ** | |
| ២៦.១ បង្កើតឱ្យមានអង្គភាព សវនកម្មផ្ទៃក្នុងនៅគ្រប់ក្រសួង | |
| -បានចាត់តាំងជនបង្គោលចំនួន ០៤ រូប សំរាប់ធ្វើការសម្របសម្រួលជាមួយក្រសួងស្ថាប័ន<br>-សារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការពង្រឹងសមត្ថភាពសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួង ស្ថាប័ន និងសហគ្រាសសាធារណៈ ត្រូវបានបញ្ចប់ និងផ្ញើជូនគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ<br>-ត្រួតពិនិត្យនិងតាមដានការបង្កើត ដំណើរការរបស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួងស្ថាប័ន និង សហគ្រាសសាធារណៈក្នុងនោះ<br>-២៥ ក្រសួងត្រូវបានបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង ( មានដំណើរការចំនួន ១១)<br>-០៣ សហគ្រាសសាធារណៈត្រូវបានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង និងមានដំណើរការ | ៤០% |
| ២៦.២ កែលម្អយន្តការដើម្បី ធានាការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពទៅនឹងលទ្ធផល សវនកម្ម និងអធិការកិច្ចនៅ តាមបណ្តាអង្គភាពថវិកា | |

| | |
|---|---|
| -បេសកកម្មសវនកម្មនៅអគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ត្រួ នាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ សាខាគយ សាខាពន្ធដារ រតនាគារ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកោះកុង បានប សាខាគយ សាខាពន្ធដារ រតនាគារ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រាជធានីភ្នំពេញ សាខាគយ សាខាពន្ធដារ រតនាគារ និងមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្តកំពង់ចាម រតនាគារខេត្តបាត់ដំបង ស្ទឹងត្រែង មណ្ឌលគិរី រតនគិរី តាកែវ ក្រចេះ ឧត្តរមានជ័យ និង ព្រះវិហារ<br>-ត្រៀមតំឡើងប្រអប់សបុត្រសវនកម្មនៅ ២៣ ខេត្ត និងរាជធានី | |
| -រៀបចំសៀវភៅព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសំរាប់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងបណ្តាសាខាក្រោមចំណុះទើបតែ សំរេចបាននៅសាខាគយ និងរដ្ឋាករខេត្តព្រះសីហនុ និងស្នាក់ការគយ និងរដ្ឋាករប៉ោយប៉ែត<br>-រៀបចំសៀវភៅព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសំរាប់អគ្គនាយកដ្ឋានពន្ធដារ និងបណ្តាសាខាក្រោមចំណុះ ទើបតែសំរេចបាននៅ នាយកដ្ឋានគ្រប់គ្រងអ្នកជាប់ពន្ធធំ | ៥% |
| ២៦.៣: រៀបចំ និងកែលំអផែនការសវនកម្ម ប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័ន ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យ វាយតំលៃហានិភ័យដែល បានផ្តល់ អនុសាសន៍ ដោយ កសហវ | |
| ផែនការសវនកម្មប្រចាំឆ្នាំ ២០០៩ និងផែនការសវនកម្ម ០៣ ឆ្នាំ រំកិល ២០០៩-២០១១ ត្រូវបានបញ្ចប់ និងផ្ញើជូនគ្រប់ នាយកដ្ឋាន និងអង្គភាពក្រោមចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អាជ្ញាធរ សវនកម្មជាតិ | ១០០% |
| ២៨.១ រៀបចំស្ថាប័នដើម្បី ឆ្លើយតបនឹងដំណាក់កាលទី ២ ដោយរួមមានៈ ការបញ្ចប់ការ វិភាគមុខងារនៅគ្រប់នាយកដ្ឋាននៃ កសហវ និង នាយកដ្ឋាន ហិរញ្ញវត្ថុ នៃក្រសួង-ស្ថាប័ន ។ រៀបចំ និង អនុវត្តផែនការ យុទ្ធសាស្ត្ររបស់នាយកដ្ឋាននីមួយៗ ។ រៀបចំ និង ផ្សព្វផ្សាយឯកសារណែនាំស្តីពី ប្រព័ន្ធគ្រប់គ្រង។ រៀបចំគោលនយោបាយសម្រាប់យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅកសហវការកសាងសមត្ថភាពនាយកដ្ឋានការប្រើប្រាស់ជំនួយបច្ចេកទេសប្រកបដោយប្រសិទ្ធភាព ។ កែលម្អការអនុវត្តការងារតាម រយៈការបង្កើនការប្រើប្រាស់បច្ចេកវិទ្យា។ | |
| -កំពុងប្រមូលលិខិតបទដ្ឋានផ្លូវច្បាប់ទាក់ទងនឹងនាយកដ្ឋាន អង្គភាពក្រោមចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានមួយចំនួន ដូចជាៈ នាយកដ្ឋានថវិកា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានរតនាគារជាតិ និង ក្រុមប្រឹក្សាជាតិគណនេយ្យ<br>-សិក្សាស្រាវជ្រាវកម្មវិធីបណ្តុះបណ្តាលរយៈពេលខ្លី នៅក្រៅប្រទេស<br>-មន្ត្រីនាយកដ្ឋានបុគ្គលិក ៣នាក់ កំពុងចូលរួមសិក្សាផ្នែក ព័ត៌មានវិទ្យានៅនាយកដ្ឋានព័ត៌មានវិទ្យា<br>-បន្តធ្វើបច្ចុប្បន្នភាពទិន្នន័យបុគ្គលិកដែលទាក់ទង : កម្រងឯកសារពាក់ព័ន្ធ ការងារគ្រប់គ្រងមន្ត្រីរាជការ ទម្រង់បែបបទឯកសារអភិក្រមការងារបុគ្គលិក<br>-បានសិក្សាលើការបង្កើតមូលដ្ឋានទិន្ន័យដើម្បីគ្រប់គ្រងសំណុំឯកសារមន្ត្រីរាជការ តាមរយៈពតិមានវិទ្យា និងថវិកាត្រូវបានឯកភាពតាមគម្រោងស្នើឡើង<br>-បន្តរៀបចំចងក្រងអភិក្រមការងារបុគ្គលិក និង វិធាននីតិវិធី និងបទបញ្ជាផ្សេងៗ ទៅតាមអភិក្រម ការងារបុគ្គលិកនីមួយៗ | ២០% |

| | |
|---|---|
| -ផ្សព្វផ្សាយគោលការណ៍វាយតម្លៃកំណត់សម្បត្តមន្ត្រីរាជការសំរាប់ការឡើងកាំប្រើវត្ស ប្រចាំឆ្នាំ២០០៩<br>-បន្តការងារជាមួយទីប្រឹក្សាត្រួតពិនិត្យវិភាគមុខងារ( ប្រជុំជាមួយអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និង អង្គភាព ចំណុះ កសហវ<br>-បានចងក្រងឯកសារពាក់ព័ន្ធបេសកកម្ម តួនាទី ភារកិច្ច រចនាសម្ព័ន្ធ របស់ក្រសួង និងអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាព ចំណុះ កសហវ<br>-បានសិក្សាលើការរៀបចំយន្តការសំរាប់អនុវត្តនីតិវិធីត្រួតពិនិត្យមុខងារ<br>-បានទំនាក់ទំនងជាមួយ CAR សិក្សាស្រាវជ្រាវឯកសារគោលនយោបាយ គ្រប់គ្រងធនធានមនុស្ស<br>-តារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋ នៅអគ្គនាយកដ្ឋានរតនាគារជាតិ គយ និងរដ្ឋាករកម្ពុជា ពន្ធដារ នាយកដ្ឋាន និងអង្គភាព :-ដី ០៩ប្លង់ -ម៉ាស៊ីនភ្លើង ០៤គ្រឿង | |
| ២៨.៣ ការកសាង និងបណ្តុះ បណ្តាលជំនាញសម្រាប់ដំណាក់ កាលទី២ ដែលមានដូចជា: ការពង្រឹកន្ទូវការកសាងជំនាញ និងរៀបចំវគ្គសិក្សាមូលដ្ឋាន។ រៀបចំជាបឋមវគ្គសិក្សាថ្មីសម្រាប់មុខជំនាញសំខាន់ៗ ។ ត្រូវចាប់ ផ្តើមដំណើរការវគ្គសិក្សាដែល កសហវ បានរៀបចំ និងរៀបចំ ផែនការកសាងសមត្ថភាពនៅតាមក្រសួង-ស្ថាប័ន ដែលស្ថិត នៅក្នុងក្របខ័ណ្ឌនៃផែនការ របស់ កសហវ ។ ស្របពេល គ្នានេះដែរត្រូវបន្តរៀបចំផែនការ បណ្តុះបណ្តាលនៅបរទេសជាពិសេសសម្រាប់ក្រុមមន្ត្រីចលករ ព្រមទាំងរៀបចំ និងអនុវត្ត ផែនការទស្សនកិច្ចសិក្សា | |
| ផែនការបណ្តុះបណ្តាលជំហានទី ២ សំរាប់គ្រប់មន្ត្រីសវនកម្មផ្ទៃក្នុង ពង្រៀងផែនការបណ្តុះបណ្តាល រយៈពេល ០៣ ឆ្នាំត្រូវ បានបញ្ចប់ និងត្រូវបានវិទ្យាស្ថានសេដ្ឋកិច្ច<br>និងហិរញ្ញវត្ថុបញ្ចូលទៅក្នុងផែនការ បណ្តុះបណ្តាលរយៈពេល ០៣ ឆ្នាំ | ២០% |
| ២៨.៤ រៀបចំឱ្យមានការលើក ទឹកចិត្តសម្រាប់ដំណាក់កាលទី២ ដែលមានដូចជា: ពិនិត្យ និង ពង្រឹកគម្រោងផ្តល់លាភការផ្អែក លើលទ្ធផលការងារ (MBPI) ដោយបន្ថែមចំនួនមន្ត្រី។ រៀបចំ វិធានការដើម្បីគាំទ្រដល់អ្នក ដែលប៉ះពាល់ដោយសារ ការផ្លាស់ប្តូរដំណើរការ និង ស្ថាប័ន។ រៀបចំអភិក្រមសម្រាប់វាយតម្លៃដើម្បីទទួលបានការ បណ្តុះបណ្តាលផ្អែកតាម តម្រូវការ។ បង្កើនឱ្យមានការ យល់ដឹង និងចូលរួមនៅក្នុង ផែនការកសាងសមត្ថភាព ។ | |
| - ធ្វើការជាមួយក្រសួងស្ថាប័នអំពីការរៀបចំគម្រោងផ្តល់លាភការ (MBPI)<br>-បានត្រួតពិនិត្យទៅលើចំនួនសកម្មភាពការងារ ចំនួនមន្ត្រីរាជការ និងសមិទ្ធកម្ម របស់នាយកដ្ឋាននីមួយៗ សំរាប់វាស់វែងសមិទ្ធិផល/យុទ្ធសាស្ត្រ<br>-បានកំណត់បែងចែកកញ្ចប់ (MBPI) ជូនអគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន នាយកដ្ឋាន និង អង្គភាព នៃ កសហវ និងបណ្តាក្រសួងស្ថាប័ន<br>-រៀបចំឯកសារពាក់ព័ន្ធនឹងការគ្រប់គ្រងការអនុវត្តប្រាក់លាភការផ្អែកលើលទ្ធផលការងារ<br>-បាន និងកំពុងបូកសរុបវាយតម្លៃលទ្ធផលការងាររបស់មន្ត្រីPFM ប្រចាំឆ្នាំ២០០៨ | ៧០ % |

## ២. បញ្ហាប្រឈម

| បញ្ហាប្រឈមដែលបាន ឬ នឹងជួបប្រទះ | | សំណើ ឬ ការស្នើឡើងនូវ សកម្មភាព ឬ វិធានការ ដើម្បីដោះស្រាយ |
|---|---|---|
| ជះឥទ្ធិពលមកលើចង្កោមសកម្មភាពការងារដែលត្រូវអនុវត្ត | ជះឥទ្ធិពលមកលើគោលបំណងឬ គោលដៅនៃសូចនាកររបស់ផែនការសកម្មភាពរួម | |
| **ក្រុមចំណូល** | | |
| ១១.១ កែសម្រួល និង អនុវត្តគោលនយោបាយ ចំណូលរយៈពេលមធ្យម | | |
| • ដំណើរការរៀបចំច្បាប់កាស៊ីណូត្រូវបានជាប់<br>• មិនមានព័ត៌មាន និង ឯកសារគ្រប់គ្រាន់ពាក់ព័ន្ធនឹង ការអនុញ្ញាតឱ្យធ្វើអាជីវកម្មឧស្ម័ន និងប្រេងកាត<br>• ខ្វះជំនាញការដើម្បីព្រាងគោលនយោបាយក្របខ័ណ្ឌ និង យុទ្ធសាស្ត្រសម្រាប់ហិរញ្ញប្បទានមីក្រូហិរញ្ញវត្ថុ និង ខ្វះ ថវិកា សំរាប់សិក្សាស្រាវជ្រាវ<br>• សមត្ថភាពមន្ត្រីជំនាញនៅមានកម្រិតនៅឡើយ ជាពិសេសជំនាញច្បាប់ កត្តាទាំងនេះ នឹងជះឥទ្ធិពដល់ការសម្រេចបាននូវ សកម្មភាពនេះ | ការមិនសម្រេចបាននូវសកម្មភាពនេះធ្វើឱ្យគោលបំណងនៃការកែលម្អគោល នយោបាយចំណូលខ្វះទិន្នន័យលើការដាក់បញ្ចូលទៅក្នុងគោល នយោបាយចំណូល | • ពន្លឿនការអនុម័តសេចក្តី ព្រាងច្បាប់កាស៊ីណូ<br>• ត្រូវការថវិកា និងជំនួយ បច្ចេកទេស ដើម្បីដំណើរការឱ្យទាន់ពេលវេលា<br>• ទាមទារការប្តេជ្ញាចិត្តខ្ពស់<br>• ត្រូវការបណ្តុះបណ្តាល មន្ត្រីដែលមានស្រាប់<br>• តម្រូវឱ្យមានមធ្យោបាយដឹកជញ្ជូនសម្រាប់ចុះត្រួត ពិនិត្យ<br>• ត្រូវការឱ្យមានការចូលរួមយ៉ាងសកម្មពីអាជ្ញាធរ ពាក់ព័ន្ធ និងមានការគាំ ទ្រពីថ្នាក់ដឹកនាំ |
| ១១.៤ បន្តកែលម្អរដ្ឋបាល និង គោលនយោបាយពន្ធដារ | | |
| • ការសើរើ និងធ្វើវិសោធនកម្មលើកិច្ចព្រមព្រៀង មិនទាន់អនុម័តនៅឡើយ<br>• មិនមានការតាមដាន និងគ្រប់គ្រងយន្តការទ្បេងទាត់លើវិទ្យាស្ថានឯកជន<br>• ខ្វះបុគ្គលិក<br>• លក្ខខន្តិកៈសមាគម ដែលពាក់ព័ន្ធនឹងការរៀបចំបង្កើត ក្រមវិជ្ជាជីវៈ និងក្រមសីលធមិសម្រាប់អ្នកមានអាជ្ញា ប័ណ្ណ និង វិញ្ញាបនប័ត្រផ្នែកអចលនវត្ថុ ការបង្កើតសមាគមអចលនវត្ថុ និងអ្នកវាយតម្លៃ | ការសម្រេចបានរបស់គោលដៅសូចនាករក៏មានការយឺតយ៉ាវផងដែរ | • ត្រូវការបណ្តុះបណ្តាល មន្ត្រីដែលមានស្រាប់<br>• តម្រូវឱ្យមានមធ្យោបាយដឹកជញ្ជូនសម្រាប់ចុះត្រួត ពិនិត្យ<br>• ត្រូវការថវិកា និងជំនួយ បច្ចេកទេស ដើម្បីដំណើរការឱ្យទាន់ពេលវេលា<br>• ជំរុញឱ្យក្រសួងមហាផ្ទៃ អនុម័តលក្ខន្តិកៈអោយបានឆាប់រហ័ស |

| | | |
|---|---|---|
| អចលនវត្ថុ នៅកម្ពុជា និង ការចូលរួមជាសមាជិកពេញលេញ នៅក្នុងសមាគមអ្នកវាយតម្លៃអចលនវត្ថុអាស៊ាន (AVA) នៅមិនទាន់បានអនុម័តពីក្រសួង មហាផ្ទៃ នៅឡើយ<br>កត្តាទាំងនេះ នឹងធ្វើការសម្រេចបានរបស់សកម្មភាពនេះ មានការយឺតយ៉ាវ | | |
| ១១.៥ បន្តកែលម្អគោល នយោបាយ និងរដ្ឋបាល ចំណូលមិនមែនសារពើពន្ធ រួមទាំងទ្រព្យសម្បត្តិរដ្ឋ | | |
| • រៀបចំប្រកាសអន្តរក្រសួង ដោយមានភ្ជាប់ល័ក្ខខ័ណ្ឌសុំ ផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត និង ចំណាយដំណើរការ ប្រមូលចំណូលជាពិសេសប្រភពចំណូលថ្មី ជាហេតុ ធ្វើឱ្យការអនុវត្តសកម្មភាពនេះមានការយឺតយ៉ាវ ។<br>• ខ្លឹមសារសារាចរណែនាំ គំរូ និងប្រពន្ធ័របាយការណ៏ ស្តីពីការប្រើប្រាស់បង្កាន់ដៃជាតិត្រូវពិនិត្យឡើងវិញ ចំពោះការដាក់ឱ្យប្រើប្រាស់នៅថ្នាក់ក្រោមជាតិ ដើម្បី ឱ្យមានសង្គតិភាព ទៅនឹងច្បាប់ស្តីពីការគ្រប់គ្រង រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។<br>• រង់ចាំការសម្រេចចិត្តរបស់ថ្នាក់ដឹកនាំ ក.សហវ ស្តីពី ការបង្កើតប្រព័ន្ធលើកទឹកចិត្ត<br>កត្តាទាំងនេះ នឹងធ្វើការសម្រេចបានរបស់សកម្មភាពនេះ មានការយឺតយ៉ាវ | ការសម្រេចបានរបស់គោលដៅសូចនាករក៏មានការយឺតយ៉ាវផង ដែរ | • គួរមានវិធានការផ្តល់ រង្វាន់លើកទឹកចិត្ត និង ចំណាយរៀបចំដំណើរ ការប្រមូលចំណូល ជាពិសេសមុខចំណូលថ្មី<br>• ត្រូវការធនធានមនុស្ស<br>• ស្នើសុំការសម្រេចចិត្តស្តីពីការបង្កើតប្រព័ន្ធលើក ទឹកចិត្ត<br>• កម្មវិធីបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ច សិក្សាត្រូវផ្តល់ជាអាទិ ភាព |
| **ក្រុមរៀបចំថវិកា** | | |
| ២១.១, ២១.៣, ២៣.១, ៣១.៣ | | |

| | | |
|---|---|---|
| សមត្ថភាពនៃការយល់ដឹងរបស់មន្ត្រីនៅមានកំរិតធ្វើឱ្យការអនុវត្តផែនការសកម្មភាពរបស់នាយកដ្ឋានមានការយឺតយ៉ាវ | សូចនាករមិនអាចសម្រេចបានតាមគោលដៅ | គួរមានវគ្គបណ្តុះបណ្តាលឱ្យបានឆាប់ និងសមស្រប។ |
| ៣២.១ រៀបចំគោលនយោបាយសម្រាប់ធ្វើសមាហរណកម្ម ថវិកា។ បន្តកែលម្អការធ្វើ សមាហរណកម្មថវិកាចរន្ត និង មូលធនតាមរយៈការបន្តអនុវត្តក្របខ័ណ្ឌចំណាយរយៈពេល មធ្យម (MTEF) ផែនការ យុទ្ធសាស្ត្រថវិកា (BSPs) និង ថវិកាតាមកម្មវិធី (BP) ។ ឆ្លុះបញ្ចាំងទិដ្ឋភាពការកាត់បន្ថយភាពក្រីក្រ និងយែនឌ័រទៅក្នុង គោលការណ៍ណែនាំស្តីពីផែនការ យុទ្ធសាស្ត្រថវិកា និងថវិកាតាម កម្មវិធី | | |
| -ការបង្កើត និង ដំណើរការក្រុមការងារថវិកា ក្នុងការរៀបចំ BSP នៅតាមក្រសួង-ស្ថាប័នមួយចំនួនមានការយឺតយ៉ាវ ធ្វើឱ្យការអនុវត្តផែនការសកម្មភាពមានការយឺតយ៉ាវ | សូចនាករមិនអាចសម្រេចបានតាមគោលដៅ | គួរមានអន្តរាគមន៍ពីថ្នាក់ដឹកនាំ សាម៉ីក្រសួង-ស្ថាប័ន |
| **ក្រុមអនុវត្តថវិកា** | | |
| ១៣.១ បន្តប្រមូលផ្តុំគណនី ធនាគាររបស់រដ្ឋាភិបាល និង ពង្រឹងគណនីទោលរបស់ រតនាគារ | | |
| - *មិនមានការសហការអោយបានពេញលេញពីក្រុមការងារប្រមូលផ្តុំគណនីរបស់ អគ្គនាយកដ្ឋានរតនាគារជាតិក្នុងការផ្តល់ឯកសារ និងការចុះពិនិត្យនូវការងារនេះ* | - *នៅមានគណនីរាយប៉ាយមួយចំនួនទៀតដែលមានវឌ្ឍនភាពយឺតក្នុងការប្រមូលផ្តុំចូលគណនីទោលរតនាគារ*<br>- ក្រសួង-ស្ថាប័ន ធ្វើការកំណត់ប្រភេទគណនីប្រាក់បញ្ញើរបស់ខ្លួនមិនបានច្បាស់លាស់<br>- ក្រសួង-ស្ថាប័ន មិនមានការសហការល្អជាមួយក្រុមការងារប្រមូលផ្តុំគណនី<br>- ក្រសួង-ស្ថាប័ន មានការតវ៉ាច្រើនលើការបង្កក និងការបិទគណនី | - *សុំការសហការពីក្រុមការងារនៃអគ្គនាយកដ្ឋានរតនាគារ ជាតិ ធនាគារជាតិ ធនាគារពាណិជ្ជ និងស្ថាប័នពាក់ព័ន្ធ*<br>- សំណើសុំអោយក្រសួង-ស្ថាប័នធ្វើការកំណត់ប្រភេទគណនីអោយបានច្បាស់ លាស់<br>- សំណើសុំអោយក្រសួង-ស្ថាប័នសហការល្អជាមួយក្រុមការងារប្រមូលផ្តុំគណនី |

| | | |
|---|---|---|
| ១៣.២ បន្តពង្រីកការប្រើប្រាស់ ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការចំណូល និងចំណាយ សាធារណៈ | | |
| - មិនមានការសហការអោយបានពេញលេញពីក្រុមការងារប្រើប្រាស់ការសាកល្បងប្រើប្រាស់ប្រព័ន្ធធនាគារពាណិជ្ជរបស់អគ្គនាយកដ្ឋានក្នុងការផ្តល់ឯកសារ និងការចូលរួមប្រជុំពិភាក្សា<br>- ក្រសួង-ស្ថាប័នខ្លះ មិនចង់ប្រើប្រាស់សេវាសម្រាប់ បើកប្រាក់បៀវត្ស ដោយគេចង់ប្រើតែភ្នាក់ងារបើកផ្តល់ម្នាក់ជំនួសវិញ | - វឌ្ឍនភាពនៅមានការយឺតយ៉ាវ<br>- | - សុំការសហការពីក្រុមការងារនៃអគ្គនាយកដ្ឋានរតនាគារ ជាតិ ធនាគារជាតិ ធនាគារពាណិជ្ជ និងស្ថាប័នពាក់ព័ន្ធ<br>- ជំរុញបន្ថែមដល់ក្រសួង-ស្ថាប័ន |
| ១៣.៣ ប្រមូលផ្តុំនិងបន្តកែលម្អ ផែនការសាច់ប្រាក់(ចាប់ផ្តើមពី ប្រចាំត្រីមាស / ប្រចាំខែ និង ចាប់ផ្តើមជាបណ្តើរៗទៅប្រចាំសប្តាហ៍ និង ប្រចាំថ្ងៃ | | |
| - ខ្វះការសហការពីអគ្គនាយកដ្ឋាន និងនាយកដ្ឋានចំណូល-ចំណាយ សកហវ<br>- មន្ត្រីពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តការងារ<br>- ខ្វះឧបករណ៍ប្រើប្រាស់ក្នុងអង្គភាព<br>- ត្រូវការលើកទឹកចិត្តផ្តល់ MBPI ដល់មន្ត្រី | - | - សុំការសហការពីអគ្គនាយក ដ្ឋាននាយកដ្ឋានក្នុង សហវ ធនាគារជាតិ ធនាគារពាណិជ្ជ និងស្ថាប័ន ពាក់ព័ន្ធ<br>- បណ្តុះបណ្តាលមន្ត្រីស្តីពីការ ចងក្រង និងរៀបចំតារាង ទិន្នន័យ |
| ១៤.១ ១៤.៤ ១៤.៥ | | |
| - ការជ្រើសរើសទីប្រឹក្សាអន្តរជាតិមិនទាន់ពេលតាមការគ្រោងទុក<br>- ការជ្រើសរើសទីប្រឹក្សាអន្តរជាតិសម្រាប់អនុវត្តសកម្មភាពមិនទាន់ពេល | - មិនអាចបង្កើតច្បាប់លទ្ធកម្មបានទាន់ក្នុងឆ្នាំ ២០០៩<br>- មិនអាចអនុវត្តអនុក្រិតថ្មី និង IRRPP បានរលូន (១៤.២) | - ជំរុញដំណើរការជ្រើសរើសទីប្រឹក្សាអន្តរជាតិអោយបានឆាប់<br>- បង្កើនការប្រជុំកែសម្រួល IRRPP រៀងរាល់ថ្ងៃ<br>- ជំរុញដំណើរការជ្រើសរើស |
| - ការជ្រើសរើសទីប្រឹក្សាអន្តរជាតិសម្រាប់អនុវត្ត | - មន្ត្រីពុំមានសមត្ថភាពក្នុងការវាយតម្លៃការអនុវត្តប្រព័ន្ធ | |

| | | |
|---|---|---|
| សកម្មភាពមិនទាន់ពេល | លទ្ធកម្ម និងផ្តល់វិមជ្ឈការលទ្ធកម្មបន្ថែមជូនដល់ ស្ថាប័ន អនុវត្តលទ្ធកម្ម ។ | ទីប្រឹក្សាអន្តរជាតិអោយបាន ឆាប់<br>- ជំរុញការចរចារចុះកិច្ចសន្យា ជាមួយជំនាញការក្នុងស្រុក។ |
| - ការបង្កើត e-PPB/Procurement Website របស់ នាយកដ្ឋានដែលត្រូវចាប់ផ្តើមដំណើរការនៅខែ កញ្ញា ឆ្នាំ២០០៩ ខាងមុខនេះ | | |
| ២៣.១ ត្រួតពិនិត្យឡើងវិញ និងបន្តកែលម្អប្លង់គណនីថ្មី និងចំណាត់ថ្នាក់ថវិកាថ្មីដើម្បីពង្រឹង នឹងអនុវត្តជាបណ្តើរៗ ចំណាត់ ថ្នាក់សេដ្ឋកិច្ច មុខងារ និង រដ្ឋបាល | | |
| - ការផ្ញើរបាយការណ៍បំណុលត្រូវទារពីអគ្គនាយក ដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធមានការយឺតយ៉ាវ | | - សូមអោយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធផ្ញើ របាយការណ៍អោយបានឆាប់ រហ័ស និងទាន់ពេលវេលា |
| ២៣.២ សិក្សា និងផ្តល់ ជម្រើសចំណាត់ថ្នាក់តាមកម្មវិធី | | |
| - ពុំទាន់មានជំនាញការ<br>- ពុំទាន់មានទស្សនកិច្ចសិក្សានៅក្រៅប្រទេស | | - សូម កសហវ រកជំនាញការអោយបានឆាប់<br>- សំណូមពរផ្ញើទស្សនកិច្ចសិក្សានៅក្រៅប្រទេស នៅ ក្នុងខែ ឧសភា ឆ្នាំ ២០០៩ |
| ២៣.៣ សិក្សា និងផ្តល់ ជម្រើសសម្រាប់ការឈានទៅ ប្រព័ន្ធគណនេយ្យបង្ករជា ជំហានៗ | | |
| - ការផ្តល់កិច្ចសហការពីអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធនៅមានកម្រិត | | - សូមអោយអគ្គនាយកដ្ឋាន និងនាយកដ្ឋានពាក់ព័ន្ធផ្តល់ កិច្ចសហការបន្ថែម |
| ២៤.២ កែលម្អដំណើរការនៃ ប្រតិបត្តិការនៅក្នុង កសហវ/ ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្រប ទៅនិងការវិវឌ្ឍន៍នៃប្លង់ គណនេយ្យ និងបទដ្ឋាន គណនេយ្យ ព្រមទាំងធ្វើការ ផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | | |
| - ការផ្តល់កិច្ចសហការពីក្រសួង-ស្ថាប័នពាក់ព័ន្ធនៅ | | - សូមឱ្យក្រសួង-ស្ថាប័នពាក់ព័ន្ធផ្តល់កិច្ច |

| | | |
|---|---|---|
| មានកម្រិត | | សហការបន្ថែម |
| ២៤.៣ បង្កើនកម្រិតយល់ដឹង ភាពជាម្ចាស់ ការចូលរួម និងសមត្ថភាពផ្នែក FMIS ដល់ កសហវ ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ | | |
| ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ផ្នែកវិភាគ នីតិវិធីអនុវត្តការងារ (Business analyst) ចំនួន ១០ រូប បានពន្យាពេលយ៉ាងយូរដែលការ ចាប់ផ្តើមប្រកាសជ្រើសរើសតាំងពីដើមឆ្នាំ ២០០៨ តែរហូតមកដល់ពេលនេះ នាយកដ្ឋានព័ត៌មានវិទ្យាពុំទាន់បានទទួលមន្ត្រីទាំងនេះនៅឡើយដែលនាំឱ្យជះឥទ្ធិពលអវិជ្ជមានមកលើសកម្មភាពទាំងអស់របស់នាយកដ្ឋាន | ធ្វើឱ្យមានការយឺតយ៉ាវដល់ដំណើរការអនុវត្តការងារពិនិត្យ និងចងក្រងឯកសារនីតិវិធីអនុវត្តការងារ (Business Process) ដែលជាការចម្បងបំផុតក្នុងការកសាងប្រព័ន្ធ អធីរ ប្រកបដោយប្រសិទ្ធភាព ម្យ៉ាងទៀតមន្ត្រីទាំងនេះត្រូវការចូលរួមក្នុងការបណ្តុះបណ្តាលជំនាញផ្នែក នីតិវិធីអនុវត្តការងារជាមុន មុននឹងមានលទ្ធភាពបម្រើការងារ | ពន្លឿនការងារជ្រើស រើសមន្ត្រីទាំងនេះ ឱ្យបានឆាប់បំផុត |
| ២៥.១ ពិនិត្យឡើងវិញនូវ ស្តង់ដារគណនេយ្យរដ្ឋបាល សាធារណៈដែលមានលក្ខណៈជាអន្តរជាតិ (IPSAS, GAAP) និង វាយតម្លៃភាពប្រាកដនិយម និងភាពសមស្របនៃលំដាប់ លំដោយក្នុងការដាក់ឱ្យអនុវត្ត ស្តង់ដារគណនេយ្យនេះដោយ ផ្សារភ្ជាប់ទៅនឹងការពង្រីកការ ប្រើប្រាស់ FMIS | | |
| - ពុំទាន់មានជំនាញការ<br>- ពុំទាន់មានទស្សនកិច្ចសិក្សានៅក្រៅប្រទេស | | - សូម កសហវ រកជំនាញ ការឱ្យបានឆាប់<br>- សំណូមពរធ្វើទស្សនកិច្ចសិក្សានៅក្រៅប្រទេសនៅ ក្នុងខែ ឧសភា ឆ្នាំ ២០០៩ |
| ២៥.៣ កែលម្អទម្រង់ របាយការណ៍អនុវត្តថវិកាដែល ត្រូវផ្ញើរទៅ គណៈរដ្ឋមន្ត្រី និងស្ថាប័ននីតិបញ្ញត្តិ | | |
| ឯកសារដេញថ្លៃដំណាក់កាលទី ២ បន្តនូវការពន្យាពេលយ៉ាងយូរ ទោះបីជាឯកសារនេះកំពុងត្រូវបានពិនិត្យមើលដោយធនាគារពិភព | រាំងស្ទះដល់ដំណើរការបន្តអនុវត្តគម្រោង អធីរទាំងមូលឱ្យទាន់តាមកាល កំណត់ ជាពិសេសអាចនាំឱ្យក្រុមហ៊ុនដែលចូលរួមក្នុងការ ដេញថ្លៃទាំង ០៤ | សំណូមពរដល់ធនាគារ ពិភពលោក ពិនិត្យមើល និងផ្តល់លិខិតមិន ជំទាស់ឱ្យបានឆាប់លើឯកសារដេញថ្លៃដំណាក់កាលទី ២ |

| | | |
|---|---|---|
| លោកក៏ដោយដែលនាំឱ្យ សកម្មភាព ២៤.៥.៣. និង សកម្មភាព ដទៃទៀតមានការរាំងស្ទះ | បាត់បង់នូវភាពអត់ធ្មត់ក្នុងការបន្តចូលរួមក្នុងការ ដេញថ្លៃ | |
| **ក្រុមគាំទ្រទូទៅ** | | |
| ២៦.២ កែលម្អយន្តការដើម្បី ធានាការឆ្លើយតបប្រកបដោយ ប្រសិទ្ធភាពទៅនឹងលទ្ធផល សវនកម្ម និងអធិការកិច្ចនៅ តាមបណ្តាអង្គភាពថវិកា | | |
| -ការរៀបចំសៀវភៅព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសំរាប់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា និងបណ្តាសាខា ក្រោមចំណុះពុំមាន ដំណើរការ ដោយខ្វះទីប្រឹក្សា<br>-ការរៀបចំសៀវភៅព្រាងនីតិវិធីសវនកម្មផ្ទៃក្នុងសំរាប់ អគ្គនាយកដ្ឋាន ពន្ធដារ និងបណ្តាសាខា ក្រោមចំណុះ ពុំ មានដំណើរការដោយ ខ្វះទីប្រឹក្សា | | សំណើសុំទីប្រឹក្សាក្នុង និងក្រៅ ស្រុក |
| ២៨.១ រៀបចំស្ថាប័នដើម្បី ឆ្លើយតបនឹងដំណាក់កាលទី ២ ដោយរួមមានៈ ការបញ្ចប់ការ វិភាគមុខងារនៅគ្រប់នាយកដ្ឋាននៃ កសហវ និង នាយកដ្ឋាន ហិរញ្ញវត្ថុនៃក្រសួង-ស្ថាប័ន ។ រៀបចំ និង អនុវត្តផែនការ យុទ្ធសាស្ត្ររបស់នាយកដ្ឋាន នីមួយៗ ។ រៀបចំ និង ផ្សព្វផ្សាយឯកសារណែនាំស្តីពី ប្រព័ន្ធគ្រប់គ្រង។ រៀបចំ គោលនយោបាយសម្រាប់ យុទ្ធសាស្ត្រគ្រប់គ្រងព័ត៌មានវិទ្យានៅ កសហវ ការកសាងសមត្ថភាពនាយកដ្ឋាន ការប្រើប្រាស់ជំនួយបច្ចេកទេស ប្រកបដោយប្រសិទ្ធភាព ។ កែលម្អការអនុវត្តការងារតាម រយៈការបង្កើនការប្រើប្រាស់ បច្ចេកវិទ្យា។ | | |
| ការងារចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ទូទាំងប្រទេស មាន ការខ្វះខាតមន្ត្រីសំរាប់ចុះ និង មធ្យោបាយធ្វើដំណើរទៅតាមព្រំដែនប្រទេស | | -បន្ថែមមន្ត្រី និងមធ្យោបាយ ធ្វើ ដំណើរ<br>-ស្នើសុំបង្កើតការិយាល័យសារពើភ័ណ្ឌ |

## ៣. សន្និដ្ឋាន (ការវាយតម្លៃជារួម អនុសាសន៍ និង សំណូមពរ)

ជារួម ការអនុវត្តសកម្មភាពកំណែទម្រង់របស់អគ្គនាយកដ្ឋាន/នាយកដ្ឋាន ក្នុងរយៈពេលពីរ ខែ (មករា និងកុម្ភៈ) មានវឌ្ឍនភាពក្នុងកម្រិតមួយដែលបានគូសបញ្ជាក់ពីការយកចិត្តទុកដាក់ និងការទទួលខុសត្រូវអនុវត្តផែនការសកម្មភាពរបស់ខ្លួន ទន្ទឹមនឹងនេះ បញ្ហាប្រឈមមួយចំនួនបានលេចឡើង ដែលត្រូវមានការគិតគូរដោះស្រាយដើម្បីធានាប្រសិទ្ធភាពការងារនៅក្នុងពេលខាងមុខ ដែលបញ្ហាប្រឈមទាំងនោះមានដូចជា:

- ពេលវេលានៃការអនុវត្តសកម្មភាព មិនអាចអនុវត្តបានតាមការគ្រោងទុកដែលបណ្តាឱ្យប៉ះពាល់ដល់ការសម្រេចគោលដៅរួម
- កិច្ចសហការរវាងអគ្គនាយកដ្ឋាន-នាយកដ្ឋាន នៅតែជាចំណុចមួយលំបាកដែលត្រូវមានការដោះស្រាយដើម្បីធានាប្រសិទ្ធភាពការងារ ទន្ទឹមនឹងនេះ ការផ្តល់ការគាំទ្រពីថ្នាក់ដឹកនាំក្នុងការដោះស្រាយបញ្ហារបស់អគ្គនាយកដ្ឋាន/នាយកដ្ឋានជាការចាំបាច់
- សមត្ថភាពមានកម្រិតរបស់មន្ត្រីរាជការ តម្រូវឱ្យមានការយកចិត្តពង្រឹងសមត្ថភាពជាប្រចាំ
- ការជ្រើសរើសទីប្រឹក្សាបច្ចេកទេស មានភាពយឺតយ៉ាវ ដែលត្រូវជម្រុញឱ្យបានឆាប់រហ័ស
- ការបែងចែកការងារក្នុងរង្វង់មន្ត្រីទទួលប្រាក់លាភការបន្ថែមដើម្បីអនុវត្តការងារកំណែទម្រង់នៅក្នុងអគ្គនាយកដ្ឋាន/នាយកដ្ឋានមួយចំនួនមិនច្បាស់លាស់ ដែលនាំឱ្យវឌ្ឍនភាពការងារនៅមានកម្រិតទាប
- ការផ្តល់របាយការណ៍វឌ្ឍនភាពមកលេខាធិការដ្ឋាន នៅតែមានភាពយឺតយ៉ាវ ដែលគួរមានយន្តការងារផ្ទៃក្នុង អគ្គនាយកដ្ឋាន/នាយកដ្ឋានឱ្យច្បាស់លាស់។

រាជធានីភ្នំពេញ, ថ្ងៃទី ខែ ឆ្នាំ២០០៩

**ហត្ថលេខា**

**ប្រធានលេខាធិការដ្ឋាន**